ភីណាមិនទាន់ហើបមាត់ឆ្លើយយ៉ាងណាផង ក៏ត្រូវនេត្រអូសដៃចេញពីបន្ទប់តម្រង់ទៅបន្ទប់មួយផ្សេងនៅជ្រុងខាងលិច។ ចូលដល់ខាងក្នុងបន្ទប់ភ្លាមកាលណាភីណាប្រទះឃើញសៀវភៅច្រើនរយក្បាលរៀបចំដោយរបៀបរៀបរយត្រឹមត្រូវពេញក្នុងផ្ទៃបន្ទប់ នាងដឹងថានេះគឺជាបន្ទប់បណ្ណាល័យដែលនេត្រក្រមុំម្ចាស់ផ្ទះទើបតែរំលឹកអម្បាញ់មិញនោះហើយ។ នៅឯជញ្ជាំងខាងលិចមានកូនបង្អួចមួយ ដែលតាមរយៈកូនបង្អួចនោះ ពិតជាអាចសម្លឹងទៅឃើញផ្ទះបាយរបស់ភីណា យ៉ាងច្បាស់ដូចសម្ដីនេត្ររៀបរាប់មែន។

ភីណាឈរក្បែរកូនបង្អួចសម្លឹងទៅកាន់ផ្ទះបាយរបស់ខ្លួនដែលស្ថិតនៅជាន់ខាងក្រោម សំឡេងនាងក្រមុំនិស្សិតបន្លឺសាជាថ្មីក្បែរត្រចៀក៖

-កាលណោះមីងសានឈរបិទបង្អួចនៅត្រង់នោះ ម្ល៉ោះហើយហេតុការណ៍ទាំងប៉ុន្មានក្នុងបន្ទប់បាយឯងត្រូវគាត់មើលឃើញអស់គ្មានសល់ទេ។

ភីណាងាកមករកនារីនិស្សិត ដោយបន្លឺសួរវិញយ៉ាងរហ័ស៖

-ចង់ ចង់និយាយថានាងអ្នកបម្រើគឺស្លាប់ក្នុងបន្ទប់បាយផ្ទះខ្ញុំ តើមែនទេ?

នាងនេត្រងក់ក្បាលផ្ងក់ៗ ដោយផ្ដោតអារម្មណ៍សម្លឹងចុះទៅកាន់បន្ទប់បាយគេហដ្ឋានដែលនៅជាប់របងខ្លួន នាងពោលតប៖

-កន្លងទៅប្រមាណជិតបួនឆ្នាំដែលមីងសានរៀបរាប់រឿងនោះប្រាប់ខ្ញុំ ប៉ុន្តែរហូតមកទល់ពេលនេះពាក្យសម្ដីប្រកបដោយក្ដីតក់ស្លុតរបស់គាត់នៅតែចងចាំជាប់ជានិច្ច! យប់នោះផ្ទះខ្ញុំគ្មានអ្នកណានៅទេ អ្នកបម្រើសុំច្បាប់ទៅស្រុក សូហ្វីរឡាន និងប៉ាចេញទៅមិនទាន់ត្រឡប់មកវិញនៅឡើយ ក្នុងផ្ទះមានតែមីងសានហើយ និងខ្ញុំប៉ុណ្ណោះ ឯសំណាងវានៅតូចជាងនេះឆ្ងាយណាស់ ដេកលក់តាំងពីព្រលប់ម្ល៉េះ ប៉ុន្តែខ្ញុំមានទម្លាប់នៅអង្គុយរៀនម្នាក់ឯងដល់យប់ជ្រៅ ជួនកាលដល់រំលងអធ្រាត្រផងក៏មានដែរ យប់នោះខ្ញុំនៅទន្ទេញមេរៀនបណ្ដើរស្ដាប់វិទ្យុបណ្ដើរ ដោយគ្មានចិត្តនឹកព្រួយបារម្ភពីរឿងអ្វីទាំងអស់ ស្រាប់តែមិនយូរប៉ុន្មានខ្ញុំបានឮសូរសំឡេងមីងសានគាត់គោះទ្វារបន្ទប់ហៅរកខ្ញុំយ៉ាងញាប់ដូចជាមានអាការភ័យរន្ធត់ភ្ញាក់ផ្អើលស្លន់ស្លោសម្បើមណាស់ កាលណោះខ្ញុំក៏នឹកភ្លាមថា ផ្ទះខ្លួនគ្មានអ្នកណានៅទេ ខ្ញុំក៏តក់ស្លុតក្នុងចិត្តដែរ ដោយស្ទុះភ្លាមទៅបើកទ្វារឲ្យមីងសាន ណាមួយមានទាំងពោលសួរយ៉ាងញាប់ទៅកាន់គាត់ថា មានរឿងអ្វីផង! ភ្លាមនេះមីងសានចូលមកដល់ក្នុងបន្ទប់ភ្លាមក៏និយាយប្រាប់

ខ្ញុំដោយទឹកមុខស្លេកស្លាំងភ្លាមដែរថា "នាងតូចនេត្រ! ខ្ញុំឃើញ ខ្ញុំឃើញ នាងកែវ នាងកែវ ស្លាប់ណា!" កាលណោះខ្ញុំនៅក្មេងស្រាប់ផង ខ្ញុំភ្ញាក់ផ្អើលហើយរន្ធត់ចិត្តឆាប់ណាស់ ខ្ញុំក្រោកពីកៅអីស្ទុះចេញទៅមើលតាមដែលមីងសានអូសដៃ គាត់អូសដៃខ្ញុំមកដល់បន្ទប់បណ្ណាល័យ រួចនាំខ្ញុំឲ្យបង្អើបបង្អួចតិចៗសម្លឹងមើលចុះទៅកាន់បន្ទប់បាយរបស់ផ្ទះឯង។

ភីណាលាន់មាត់សួរភ្លាមក្នុងពេលនោះ៖

-កាលណោះឯងប្រទះឃើញអ្វីខ្លះ?

នេត្រនៅលេបទឹកមាត់បន្តិច ទើបឆ្លើយតបវិញ៖

-អត់ទេ! ទ្វារបង្អួចបន្ទប់បាយឯងត្រូវបានបិទជិតឈឹងទៅហើយ ខាងក្នុងនោះមានអ្វីខ្លះក៏ខ្ញុំមិនអាចមើលដឹងដែរ ប៉ុន្តែភីណាសម្លឹងមុខនេត្រដោយមិនអស់ចិត្ត នាងពោលសួរភ្លាមយ៉ាងរហ័ស៖

-ប៉ុន្តែយ៉ាងម៉េច?

ក្រមុំម្ចាស់ផ្ទះបន្លឺមួយៗដោយភ្នែកនៅតែផ្តោតសម្លឹងទៅកាន់បន្ទប់បាយផ្ទះភីណា៖

-ប៉ុន្តែទោះជាយប់នោះបង្អួចនៃបន្ទប់បាយឯងត្រូវគេបិទជិតឈឹងក៏ដោយ ខ្ញុំនៅមើលឃើញថាភ្លើងក្នុងបន្ទប់នោះនៅបើកភ្លើងចិញ្ចាចមិនទាន់បានពន្លត់នៅឡើយ បញ្ជាក់ថាខាងក្នុងនោះនៅមានមនុស្សកំពុងធ្វើអ្វីម្យ៉ាងទាំងយប់អធ្រាត្រច្បាស់ណាស់!

ភីណានៅស្ងៀមដោយសញ្ជឹងគិត ស្មានមិនដល់ថាបានស្គាល់អ្នកជិតខាងម្នាក់នេះ ក៏បានស្តាប់រឿងចម្លែកៗដែលខ្លួនមិនធ្លាប់ដឹងច្រើនយ៉ាងនេះសោះ ខណៈនោះនាងពោលសួរវិញភ្លាមដែរ៖

-អញ្ចឹងម៉េចក៏ឯងដឹងថា គឺ គឺនាងអ្នកបម្រើនោះត្រូវស្លាប់ក្នុងបន្ទប់បាយ?

នេត្រទាញដៃភីណាឲ្យមកដាក់បង្គុយលើសាឡុងទល់មុខនឹងទូសៀវភៅដែលតម្រៀបជាជួរៗរាប់រយក្បាល! នេត្រពោលតបតាមដំណើររឿង៖

-ដូចខ្ញុំប្រាប់ឯងតាំងពីដំបូងអញ្ចឹង គឺខ្ញុំបានជជីកសួររឿងនេះពីមីងសាន គាត់ក៏បាននិយាយអស់ប្រាប់ខ្ញុំពីអ្វីដែលគាត់បានឃើញក្នុងយប់នោះ!

-គាត់ថាម៉េចខ្លះ? ពីដំបូងមកគឺយ៉ាងម៉េចខ្លះ? (ភីណាបើកភ្នែកមូលក្លំ ពោលសួរមកកាន់ក្រមុំនិស្សិតដោយចិត្តអន្ទះសា)

-គាត់ថា គឺគាត់បានឃើញដោយផ្ទាល់ភ្នែករឿងដែលនាងកែវត្រូវគេវាយសម្លាប់ក្នុងបន្ទប់បាយរបស់ឯង!

ភីណាធ្លាក់ថ្លើមក្អុក "វាយសម្លាប់"? ពាក្យនេះជាសម្ដីគួរឲ្យភ្ញាក់ផ្អើលមួយ ដែលខ្លួនទើបតែបានឮនឹងត្រចៀកជាលើកដំបូងបង្អស់ នាងមិនទាន់បានពោលសួរគូសន្ទនាតាមសន្ទុះចិត្តដែលងឿងឆ្ងល់ផង ភ្លាមនោះនាងឮនារីនិស្សិតពោលបន្ថែមទៅហើយ៖

-មីងសានរៀបរាប់ប្រាប់ខ្ញុំច្បាស់លាស់ណាស់ថា យប់នោះក៏ដូចរាល់យប់ដែរ គាត់ឧស្សាហ៍ឡើងមកទីនេះអើតសម្លឹងនាងកែវ ជួនកាលស្ដាប់ពាក្យសោយសោកអាណិតខ្លួនរបស់នាងកែវដែលជានារីកំព្រានោះទៀតផង ប៉ុន្តែនៅយប់ដែលមានកើតរឿងហេតុនោះ គាត់មិនទាន់បាននិយាយទៅរកនាងកែវមួយម៉ាត់ណានៅឡើយត្បិតអីកាលណោះ ពេលគាត់បើកបង្អួចទៅគឺឃើញនាងកែវកំពុងរៀបចំលាងចានកែវ គាត់គិតថាចាំដល់នាងរៀបចំរួច ទើបនិយាយសាសងជាមួយនាងគ្រាន់ឲ្យនាងបានធូរចិត្តពីការលំបាកខ្លះ ប៉ុន្តែភ្លាមនោះក៏ស្រាប់តែមានរឿងរ៉ាវកើតឡើងរហូតដល់គាត់ស្មានមិនដល់ ត្បិតអីគាត់ឃើញសេដ្ឋីម្ចាស់ផ្ទះដើរលបៗចូលមកក្នុងបន្ទប់បាយរួចចាប់ឱបនាងកែវពីក្រោយដោយអាកប្បកិរិយាថោកទាបគួរឲ្យស្អប់ខ្ពើមជាទីបំផុត មីងសានរំលឹកថាកាលណោះគាត់ឃើញនាងកែវកំពុងរើបម្រះក្រោមក្រញាំស្រេកឃ្លានរបស់សេដ្ឋី គាត់កើតក្ដីស្លន់ស្លោណាស់ដោយមិនដឹងថាគួរតែជួយនារីកម្សត់នោះដោយរបៀបណាឡើយ ប៉ុន្តែភ្លាមនោះក៏ស្រាប់តែលេចរូបប្រពន្ធសេដ្ឋីចូលមកដល់ មីងសានគាត់នឹកអរដោយគិតថាច្បាស់ជានាងកែវលើកនេះបានរួចខ្លួនទៅហើយ ប៉ុន្តែមិនស្មានដល់ថាលទ្ធផលប្រែជាផ្ទុយស្រលះទៅវិញទេ។

ភីណាបើកភ្នែកមូលក្លំសម្លឹងទៅកាន់នារីនិស្សិតដោយជក់ចិត្តនឹងពាក្យសម្ដីដែលគេកំពុងរៀបរាប់ប្រាប់ខ្លួន ភ្លាមនោះដៃរនាងក្រមុំម្ចាស់ផ្ទះពោលបន្ត៖

-ប្រពន្ធសេដ្ឋីនោះមិនត្រឹមតែមិនបន្ទោសប្ដីដែលប្រព្រឹត្តអំពើលាមកទៅលើអ្នកជ្រកកោនជាមួយទេ គឺថែមទាំងទម្លាក់កំហុសទាំងស្រុងមកលើនាងអ្នកបម្រើ ដោយទាញបោចសក់វាយ

តប់នាងយ៉ាងដំណំ ណាមួយមានទាំងជេរប្រមាថថានាងព្យាយាមលួចលាក់សហាយស្មន់ដណ្ដើមប្ដីគាត់ទៀងផង។

ភីណាស្ដាប់បណ្ដើរ នាងរអ៊ូដោយមិនដឹងខ្លួនបណ្ដើរ៖

- ស្ត្រីនោះយ៉ាប់មែនហើយ! កំណាចណាស់!

នេត្រពេបមាត់គ្រវីក្បាលឃីតៗដោយពោលបន្តពីសម្ដីភីណា៖

-មិនត្រឹមយ៉ាប់ទេ គឺសាហាវយង់ឃ្នងទៀងផង កាលណោះគាត់វាយដំនាងកែវជាអ្នកបម្រើយ៉ាងដំណំប៉ុណ្ណឹងហើយក៏នៅមិនទាន់អស់ចិត្តទៀត លុះប្ដីគាត់ពោលឃាត់ គាត់រឹតតែផ្ទុះកំហឹងខ្លាំងជាងមុន ដោយស្រវាទាញកូនកាំបិតចិតផ្លែឈើមកចាក់នាងកែវសម្លាប់តែម្ដង មីងសានរៀបរាប់ដោយតក់ស្លុតថាយប់នោះគាត់បានឃើញយ៉ាងច្បាស់ផ្ទាល់នឹងភ្នែកថានាងអ្នកបម្រើកម្សត់នោះត្រូវថៅហ្វាយស្រីវាយផង ចាក់នឹងកាំបិតផង រហូតទាល់តែស្លាប់ស្ដូកស្ដឹងលើកម្រាលឥដ្ឋ លុះឃើញថាខ្លួនបានសម្លាប់គេឲ្យស្លាប់ហើយ ប្ដីប្រពន្ធនេះក៏មានអាការតក់ស្លុតណាស់ដែរ ប៉ុន្តែក្រោយមកគាត់ទាំងពីរធ្វើយ៉ាងម៉េចចំពោះសាកសពនាងកែវក៏គ្មានអ្នកណាដឹងដែរ ត្បិតអីកាលណោះពេលមីងសានចេញទៅហៅខ្ញុំ លុះដល់មកវិញបង្អួចបន្ទប់បាយត្រូវបានបិទយ៉ាងជិតទៅហើយ ពីរនាក់ប្ដីប្រពន្ធនោះយកសពនាងកែវទៅកប់ឬក៏បោះចោលនៅទីណាក៏យើងមិនដឹងដែរ ប៉ុន្តែក្រោយពីយប់កើតហេតុនោះបានបួនប្រាំថ្ងៃមក ក៏ស្រាប់តែសេដ្ឋីពីរនាក់ប្ដីប្រពន្ធនោះរៀបចំចាកចេញពីផ្ទះ ដោយប្រគល់ផ្ទះទៅឲ្យក្រុមហ៊ុនទិញលក់បាត់ស្រមោលគាត់ទាំងពីរនាក់តាំងពីពេលនោះរហូតមក មិនដឹងជានៅក្នុងស្រុកនៅឡើយ ឬក៏នៅបរទេសទៅហើយទេ!

ភីណាពោលសួរវិញដោយអាការងឿងឆ្ងល់ពេញប្រៀបលើផ្ទៃមុខនៅឡើយ៖

-ចុះកាលណោះ មីងសានរបស់ឯងបានឃើញរឿងនោះផ្ទាល់ភ្នែក ម៉េចក៏រឿងធំយ៉ាងនេះហើយ បែរជាមិនព្រមទៅប្ដឹងប៉ូលិស?

នេត្រដកដង្ហើមធំតបដោយឈ្ងោកមុខ៖

-បួនឆ្នាំមុនជាមួយឥឡូវនេះគឺផ្សេងពីគ្នា គ្នាមានការយល់ដឹងតិចជាងការភ័យខ្លាចឆ្ងាយណាស់ កាលណោះក៏ជិតដល់ពេលគ្នាចេញទៅស្រុកក្រៅរៀនទៀត លុះដល់ត្រឡប់មកវិញ

នេះមីងសានគាត់អនិច្ចកម្មបាត់ទៅហើយ ឯរឿងអាថ៌កំបាំងរបស់ប្តីប្រពន្ធអ្នកមានអមនុស្សធម៌ពីរនាក់នោះក៏ត្រូវកប់បាត់យ៉ាងស្ងាត់ជាងបួនឆ្នាំកន្លងមកហើយដែរ ឥឡូវនេះនឹកឡើងវិញគួរឲ្យសោកស្តាយហើយបន្ទោសខ្លួនឯងណាស់ មិនសមណាបានដឹងរឿងហេតុហើយបែរជាបណ្តាលឲ្យឃាតកគ្មានមនុស្សធម៌រួចខ្លួនពីរង្វង់ច្បាប់ដោយងាយអញ្ចឹងទេ!

ភីណាក្រពាត់ដៃផ្អែកខ្នងនឹងបង្អែកសាឡុង តាមពិតគឺនាងកំពុងរិះគិត ម៉េចក៏ផ្ទះខ្លួនដែលនឹកថាជាទីកន្លែងដែលអាចអាស្រ័យបានសុខសាន្ត ក៏បែរជាកន្លែងធ្លាប់សម្លាប់មនុស្សយ៉ាងនេះវិញ។ នាងកំពុងលង់ទៅក្នុងការត្រិះរិះក៏ពិតមែន ប៉ុន្តែអារម្មណ៍នៅប្រមូលផ្តុំចាំស្តាប់សម្តីរបស់នេត្រនៅឡើយ ខណៈនោះដែរនាងឮនាងក្រមុំនិស្សិតរូបនោះពោលឡើងបន្ត៖

-ខ្ញុំត្រឡប់មកវិញភ្លាម ក៏បានឮអ្នកជិតខាងជុំវិញទីនេះគេរៀបរាប់ថា"មានខ្មោច" ក្នុងផ្ទះរបស់ឯង គេថែមទាំងនិយាយប្រាប់មកខ្ញុំទៀតថាតាំងពីពេលដែលសេដ្ឋីប្តីប្រពន្ធឈប់នៅទីនេះម្ល៉េះ ក៏មានមនុស្សទិញផ្ទះនេះស្នាក់នៅ ច្រើនអ្នកមកហើយ ប៉ុន្តែគ្មានអ្នកណាអាចនៅយូរបានទេ ច្រើនណាស់ម្តៃថ្ងៃប៉ុណ្ណោះ គេនាំគ្នាប្រគល់ផ្ទះទៅឲ្យក្រុមហ៊ុនទិញលក់វិញភ្លាម លុះដល់គ្រួសារឯងរើមកនៅ ស្រាប់តែនៅបានជិតពីរខែមកនេះ ធ្វើឲ្យពួកគេភ្ញាក់ផ្អើលណាស់។ ខ្ញុំបានទាំងឮគេនាំគ្នាសន្និដ្ឋានថា ប្រហែលមកពីផ្ទះនេះមានខ្មោចអញ្ចឹងហើយទើបបានប្តីប្រពន្ធសេដ្ឋីនោះរើចេញ ប៉ុន្តែសម្រាប់ខ្ញុំវិញខ្ញុំជឿថាឃាតកពីរអ្នកនោះមកតែពីខ្លួនបានសម្លាប់មនុស្សនៅទីនេះ ដូច្នេះហើយមិនអាចរស់នៅដោយសុខសាន្តបានក៏រើចេញឲ្យឆ្ងាយទៅ ក្រែងបានស្ងប់ចិត្តខ្លះ! រីឯរឿងដែលថាមានខ្មោចលងនោះ ពីដំបូងខ្ញុំក៏មិនជឿដែរ ប៉ុន្តែយប់មិញកាលខ្ញុំលួចចូលទៅផ្ទះឯង ខ្ញុំ និងប្អូនបានឃើញរូបរាងមនុស្សស្រី បណ្តែតខ្លួនពីបន្ទប់មួយទៅបន្ទប់មួយមែន កាលណោះខ្ញុំភ័យណាស់ អញ្ចឹងហើយទើបនាំគ្នារត់ទៅពួនក្នុងបន្ទប់ឯង អ៊ូនែ៎! បើខ្ញុំនិយាយទៅតើឯងជឿទេ? ខ្ញុំសង្ស័យថាខ្មោចនោះប្រាកដជានាងកែវនោះហើយ!

ភីណាឈ្ងោកមុខ នាងរអ៊ូតិចៗតបទៅវិញ៖

-ប៉ុន្តែខ្ញុំនៅជាមួយខែមកហើយ មិនដែលឃើញអីទេ!

នេត្រសម្លឹងមុខភីណាដោយក្រសែភ្នែកព្រួយបារម្ភ នាងឧទានមកកាន់ភីណា៖

-ទោះយ៉ាងណា ខ្ញុំបានឃើញផ្ទាល់នឹងភ្នែកទៅហើយ ឯងជឿឬមិនជឿ ខ្ញុំនៅតែរំលឹកឯងថាផ្ទះឯងមានខ្មោចពិតមែន។

ភីណាសម្លឹងមុខនារីម្ចាស់ផ្ទះដោយមិនចេញស្តី។ យប់នោះត្រឡប់មកផ្ទះវិញនាងក្រមុំដេកសញ្ជឹងគិតមិនចេះអស់មិនចេះហើយ ពីបញ្ហាទាំងប៉ុន្មានដែលខ្លួនជួបនឹងបានឮ តើពិតជាមានខ្មោចនាងកែវដូចដែលនេត្រនិយាយប្រាប់មែនអ្ហេស៎?

**ភាគទី១១**

យប់កាន់តែជ្រៅ ភីណានៅតែគេងមិនលក់ សេចក្តីងឿងឆ្ងល់ នឹងខ្វល់ខ្វាយចេះតែកើតមានទន្ទឹមគ្នាក្នុងចិត្តនាងក្រមុំមិនឈប់ឈរ ទោះជាប្រឹងធ្មេចភ្នែកយ៉ាងណាក៏នៅតែមិនស្កប់ចិត្តសោះ។ ពេលវេលាចេះតែកន្លងទៅមុខ នាងក្រមុំនៅសំងំក្នុងបន្ទប់ ប៉ុន្តែក៏នៅផ្ទៀងត្រចៀកស្តាប់ក្រែងមានឮសូរអ្វីប្លែកពីខាងក្រៅទៀតដែរ ប៉ុន្តែស្ងាត់ច្រៀប ស្នូរមូសយំមួយក៏គ្មានផងណាមួយថ្ងៃនេះបងប្រុសខ្លួន គាត់ត្រឡប់មកដល់ផ្ទះតាំងពីព្រលប់ម្ល៉េះ អញ្ចឹងហើយនាងក្រមុំមិនសូវជាបារម្ភខ្លាចប៉ុន្មានឡើយ។ ប៉ុន្តែប្រាសខ្លួនចុះឡើងយូរទៅកាន់តែដឹងថាដេកមិនលក់ទេ ហេតុនេះទោះប្រឹងសម្ងំក៏ឥតប្រយោជន៍ដែរ នាងក្រមុំក្រោកអង្គុយឱបជង្គង់សម្លឹងទ្រនិចនាឡិកាដែលចង្អុលថាម៉ោងមួយរំលងអាធ្រាត្រទៅហើយ នាងនឹកភ្នកដល់កាលពីព្រឹកពេលដែលខ្លួនឆ្លងទៅលេងផ្ទះនារីនិស្សិតដែលនៅជិតខាង នាងបានមើលរបៀបចៀនសាច់ និងមុខអាហារជាច្រើនទៀត កណ្តាលអធ្រាត្រសន្សើមបែបនេះនឹកទៅក៏ដូចជាចង់រកអ្វីមកបំពេញក្រពះដែរ បើធ្មេចមិនលក់អញ្ចឹងដដែលចុះទៅធ្វើម្ហូបលេងទៅមិនល្អម្យ៉ាងទេ?

គិតឃើញដូច្នោះភ្លាមតរុណីក្រោកក្រេសបើកទ្វារបន្ទប់ចុះសំដៅទៅជាន់ខាងក្រោមភ្លាម។

កណ្តាលរាត្រីស្ងាត់សូន្យ បន្ទប់ធំខាងក្រោមនេះស្ងាត់ច្រៀប ទោះជាបើកភ្លើងបំភ្លឺឲ្យភ្លឺហើយក៏នៅតែមិនគួរឲ្យទុកចិត្តសោះ ព្រោះថាផ្ទៃបន្ទប់ល្វឹងពេកហើយគ្មានមនុស្សម្នាក់ផង។ មាណវីទទួលអារម្មណ៍នៅមិនសុខចំពោះមុខបរិយាកាសនេះសោះ ល្ហើយចុះ! គួរតែត្រឡប់ឡើងទៅលើវិញទើបល្អ នាងប្រុងបែរខ្លួនត្រឡប់ឡើងទៅកាន់បន្ទប់វិញទៅហើយ ក៏ស្រាប់តែចុងកន្ទុយភ្នែកដូចជាចាប់អារម្មណ៍ឃើញថាទ្វារបន្ទប់បាយដែលនៅឯជ្រុងខាងកើត ហាក់បីដូចជាមានជះភ្លើងអគ្គិសនីចេញមកព្រាលៗនៅឡើយ វាមិនខុសអ្វីទៅហ្នឹងពន្លឺជះចេញពីទូ

ទឹកកកដោយមានអ្នកណាម្នាក់កំពុងលបបើកវា?។ ឬមួយថាយប់ថ្មើរណោះហើយ មានអ្នកបម្រើណាម្នាក់មិនទាន់ចូលដេកទៀត?

ប៉ុន្តែដូចជាមិនសមសោះ អម្បាញ់មិញកាលនៅខាងលើខ្លួនបានឃើញនាឡិកាចង្អុលដល់ម៉ោងមួយរំលងអធ្រាត្រទៅហើយ ទោះមនុស្សមានចិត្តយ៉ាងណាក៏មិនមែនក្រោកធ្វើការចោលដំណេកទាំងយប់អធ្រាត្របែបនេះដែរ ណាមួយផ្ទះក៏ដូចជាគ្មានការងារអ្វីច្រើនដែលធ្វើរហូតដល់យប់ជ្រៅសោះ ចុះតើអ្នកណាចូលចង្ក្រានធ្វើអ្វី? ភីណាដើរមួយៗសំដៅទៅទីនោះជើងកាន់តែចូលទៅជិតត្រចៀកកាន់តែបានឮសូរមនុស្សបើកទូទឹកកក ដូចជាកំពុងរៀបចំចម្អិនអាហារ ភីណានឹកចម្លែកក្នុងចិត្តតែម្នាក់ឯង ឬមួយក៏មានសមាជិកក្នុងផ្ទះណាម្នាក់ ក៏កើតរោគដេកមិនលក់ ចុះមកធ្វើម្ហូបកែអផ្សុកផងដែរ?

នាងក្រមុំសសៀរចូលទៅជិតមាត់ទ្វារបន្ទប់បាយ ចិត្តមួយត្រិះរិះបណ្ដើរថាតិចលោបងប្រុសទេដឹង នាងនៅចាំថាកាលពីល្ងាចគាត់ពិសាបាយតែបន្តិចផង ក្រែងលោគាត់នឹកឃ្លានក៏ក្រោកមករកអ្វីក្នុងទូទឹកកកពិសាទៅ ប៉ុន្តែចុះបើ មិនមែនបងប្រុស?

អារម្មណ៍មិនធម្មតាមួយលេចភ្លែតក្នុងចិត្តនាងក្រមុំ នាងនឹកដល់សម្ដីរបស់នារីនិស្សិតកាលពីព្រឹកដែលក្រមុំម្នាក់កាលពីប្រមាណបួនឆ្នាំមុន តឹងតែងបំផុតនោះគឺកន្លែងដែលនាងស្លាប់ គឺបន្ទប់បាយនេះឯង។

ភីណាថយក្រោយអែបចេញទៅម្ខាងទាំងបេះដូងលោតញាប់ខុសសង្វាក់ ថ្មីៗនេះអ្នកជិតខាងសុទ្ធតែបង្ហើបឲ្យដឹងថាផ្ទះខ្លួននេះមិនស្រួល ប៉ុន្តែខ្លួនចូលមកនៅបានយូរដែរហើយបែរជាមិនមានប្រទះឃើញអ្វីសោះ ចុះបើយប់នេះ គឺជាការចាប់ផ្ដើម? ភីណាលើកដៃជ្រោងសក់ឲ្យផាត់ទៅក្រោយទាំងអស់ ណាមួយក៏ឆ្លៀតពង្រឹងចិត្តឲ្យបានរឹងមាំជាងមុនផង នាងឆ្លៀតកម្លាចិត្តខ្លួនដោយរិះគិតថា៖

-ខ្លាចធ្វើអ្វី ក្នុងផ្ទះយើងទេតើ! បើមានខ្មោចមែន ក៏គួរតែឃើញឲ្យច្បាស់ម្ដងទៅចុះ!

នាងឈានសាជាថ្មីចូលទៅជិតបន្ទប់បាយ តរុណីយើងអែបខ្លួនទៅនឹងមាត់ទ្វារអើតសម្លឹងទៅខាងក្នុង ក្រសែភ្នែកដំបូងបង្អស់របស់នាងគឺវាត់ទៅកាន់កន្លែងទូទឹកកក ត្បិតអីខ្លួនបានឮសូរបើកទូទឹកកកអម្បាញ់មិញច្បាស់ណាស់។ ក្រសែភ្នែកបោះសម្លឹងសំដៅទៅទីនោះភ្លាមស្ទើរនឹងគាំងទន់ជង្គង់ដួលនៅនឹងកន្លែង ព្រោះថានៅចំពីមុខកែវភ្នែកទាំងគូ ភីណាបានឃើញរូប

បងស្រីថ្លៃរបស់ខ្លួនទាំងសាច់ទាំងឈាម វីវរបំផុតនោះគឺនៅលើដៃគាត់កំពុងកាន់ដុំសាច់គោស្រស់ ឈ្ងោកខាំហែកទំពាលេចទាំងឆៅ ឈាមសត្វពណ៌ក្រហមក្រមៅប្រតាកជុំវិញមាត់គាត់ដែលកំពុងឱនបរិភោគដោយអាការស្រេកឃ្លានយ៉ាងខ្លាំងក្លា។

ភីណាបើកភ្នែកធំៗព្រោះមិនដឹងថានេះគឺជាការពិតឬក៏ស្រមៃទេ ប៉ុន្តែនាងនៅតែមិនអាចកុហកខ្លួនឯងបានដដែល ការពិតវានៅតែជាការពិត បងថ្លៃដែលនាងកំពុងឃើញនេះគឺគាត់លែងជាមនុស្សទៀតហើយ! គាត់មិនមែនជាមនុស្សទៀតឡើយ! គាត់បរិភោគសាច់ឆៅ ស្និទ្ធជាមួយនឹងគ្រឿងចម្អាបកខ្វក់បែបនេះ តាមពិតគឺជាព្រាយបិសាចទើបត្រូវជាង។ នឹកដល់ត្រង់ណេះភ្លាម នាងក្រមុំរន្ធត់ចិត្តស្ទើរដួលសន្លប់ នាងហាមាត់ស្រែកយ៉ាងអស់ទំហឹង ប៉ុន្តែសូរសំឡេងស្រែករបស់នាង មិនបានធ្លាយចេញផុតពីក្រអូមមាត់នៅឡើយទេ ព្រោះថាមានបាតដៃមួយកំពុងគ្របជាប់លើប្រអប់មាត់ទៅហើយ។

មាត់មិនអាចស្រែកបានប៉ុន្តែភ្នែកនៅតែមើលឃើញដដែលនូវហេតុការណ៍គួរឲ្យព្រឺសាច់ ស្រីម្នាក់ដែលនៅក្នុងបន្ទប់បាយនោះកំពុងឈ្ងោកហែកទំពាសាច់គោយ៉ាងស្រេកឃ្លាននៅចំពោះមុខភីណាស្រស់ៗមែន។ នាងក្រមុំទប់ស្កាត់ការរំជួលចិត្តលែងបានទៀតហើយ នាងដឹងថាចង្វាក់បេះដូងហាក់ដូចជាលែងចង់លោតតទៅទៀត រីឯដៃជើងក៏រសេះរសោះក្បាលវិលខ្វាល់ភ្នែកក៏ស្រវាំងទៅៗ បន្ទាប់មកគឺខ្លួនប្រាណទាំងមូលកំពុងទន់ភ្លៀកដួលទៅក្នុងរង្វង់ដៃអ្នកណាម្នាក់ដែលនាងក្រមុំមិនបានស្គាល់មុខនៅឡើយ។

## វគ្គទី៥

## កំហឹងឆាបឆេះ

សំឡេងស្រែកហៅតិចៗលាន់ឮមិនឈប់ឈរក្បែរត្រចៀកភីណា ដឹងថាមានគេកំពុងព្យាយាមស្រែកហៅខ្លួនប៉ុន្តែនាងចង់បើកភ្នែកឲ្យឃើញមុខគេគឺលំបាកណាស់ ព្រោះថាភ្នែកទាំងគូកំពុងធ្ងន់ត្របកដូចបានផ្ទុកទម្ងន់រាប់ពាន់គីឡូ ដូច្នោះដែរ បបូរមាត់វិញចង់ហើបឆ្លើយតបនឹងអ្នកហៅក៏ប៉ុន្តែហើបមាត់មិនរួចសោះ រាងកាយទាំងមូលប្រៀបបីដូចជាកំពុងគាំងចលនា មានតែត្រចៀកប៉ុណ្ណោះទេដែលអាចប្រើការការបានច្បាស់ជាងគេ។ សម្លឹងហៅនៅតែបន្តមិនឈប់ឈរក្បែរត្រចៀក ភីណាជ្រួញចិញ្ចើមប្រឹងហើបមាត់ឆ្លើយតបយ៉ាងលំបាកៈ

-ចាំ!

សូរសព្ទនាងក្រមុំលាន់ឡើងខ្សោយយ៉ាងណាក៏ដោយ ក៏ល្មមធ្វើឲ្យក្រមុំម្នាក់ទៀតដែលកំពុងអង្គុយក្បែរស្រែកហៅឈ្មោះនាងមិនឈប់ឈរនោះត្រេកអរក្នុងចិត្តបន្តិចដែរ នាងប្រឹងលូកដៃអង្រួនភីណាទាំងមាត់ស្រែកហៅមិនឈប់៖

-ភីណា! ភីណា! ភីណា! ៗ

នាងក្រមុំភីណាជ្រួញចិញ្ចើមប្រែខ្លួនតិចៗពីក្រោមសូរសំឡេងស្រែកហៅរបស់ក្រមុំនិស្សិត។ នេត្រនាងមានសង្ឃឹមក្នុងចិត្តច្រើនជាងមុនកាលបើឃើញភីណារើខ្លួនយ៉ាងដូច្នេះ នាងនៅបន្តឱនឈ្មោះភីណាតិចៗមិនឈប់ឈរ៖

-ភីណា ដឹងខ្លួនឡើង ដឹងខ្លួនឡើងភីណា! ភីណា!

ក្រមុំរូបស្រស់បើកភ្នែកព្រឹមៗ សន្សឹមៗសម្លឹងម្ចាស់សំឡេងហៅនាងហើបមាត់ពោលសួរខ្សាវៗ៖

-នេត្រ? ឯងទេ? ខ្ញុំកំពុងតែយ៉ាងម៉េចហ្នឹង?

ក្រមុំឈ្មោះនេត្រញញឹមសម្លឹងភីណាដោយអាការឈឺឆ្អាលយកចិត្តទុកដាក់៖

-ដឹងខ្លួនហើយអ្ហេស៎?

ភីណាជ្រួញចិញ្ចើមដៀងភ្នែកសម្លឹងជុំវិញខ្លួន នាងមើលស្គាល់ថានេះគឺជាបន្ទប់ដេករបស់ខ្លួន នាងកំពុងស្ថិតនៅលើគ្រែរបស់ខ្លួន ដូចជាគ្មានអ្វីគួរឲ្យព្រួយបារម្ភសោះ ប៉ុន្តែមិនមែនធម្មតាអញ្ចឹងឯណា រឿងហេតុដ៏គួរឲ្យព្រឺសាច់នោះ បានផុសឡើងក្នុងអារម្មណ៍សាជាថ្មី ភីណាបើកភ្នែកធំៗស្ទុះក្រោកអង្គុយយ៉ាងរហ័ស នាងងាកមករកនារីនិស្សិតដោយពោលប្រាប់ញាប់មាត់ស្មេរ៖

-នេត្រ ខ្មោចណ៎ា! ខ្ញុំឃើញខ្មោច! ខ្មោចនៅបន្ទប់ចង្ក្រាន ខ្មោចមែន! គួរឲ្យខ្លាចណាស់!

សម្លឹងទ្រនិចនាឡិកាដែលចង្អុលដល់ម៉ោង៤ទៀបភ្លឺទៅហើយ នាងងាកមករកនារីនិស្សិតដែលកំពុងអង្គុយក្បែរខ្លួន នាងពោលសួរដោយមិនអស់ចិត្ត៖

-នេត្រអ្ហា! មិនទាន់ភ្លឺទេ? អ្ហះ?

នេត្រងើបមុខសម្លឹងទៅនាងក្រមុំម្ចាស់បន្ទប់ដែលប្រកបដោយអាការដូចជាមិននឹងនសោះ នាងពោលតបតិចៗស្រាលៗ៖

-មិនទាន់ភ្លឺទេ! អម្បាញ់មិញឯងសន្លប់ខ្ញុំ និងអូនសំណាងគ្រាងឯងឡើងមក!

ភីណាបង្ហាញភាពភ័យខ្លាចលើផ្ទៃមុខខ្លាំងជាងមុន នាងពោលដោយរញីរញ័រ៖

-ស្រី.....ស្រីនោះ.....មិនមែនមនុស្សទេ.....ខ្មោច.....គឺខ្មោចពិតមែន! គួរឲ្យខ្លាចណាស់!

នេត្រងក់ក្បាលដោយទឹកមុខខ្វល់ខ្វាយ នាងពោលមកកាន់ភីណាវិញដែរ៖

-ខ្ញុំឃើញហើយ! អម្បាញ់មិញឯងស្ទើរតែភ្លាត់មាត់ស្រែកឲ្យស្រីខ្មោចនោះដឹងខ្លួនទៀតផង បើខ្ញុំមិនខ្ទប់មាត់ឯងទាន់ទេស្រីនោះវាមុខតែលងឯងមិនខាង!

ភីណាបើកភ្នែកធំៗដោយសញ្ជឹងគិត នាងនឹកឃើញហេតុការណ៍កាលពីយប់ដែលមានភ្លៀងធំនោះសាជាថ្មី ថ្ងៃនោះខ្លួនបានឃើញផ្ទាល់នឹងភ្នែកថាបងថ្លៃខ្លួនធ្លាក់ពីជាន់ខាងលើមកប៉ះនឹងជើងសាឡុងយ៉ាងដំណំ គឺបានដាច់ខ្យល់ស្លាប់បាត់ទៅហើយ ថ្ងៃនេះគាត់ក្លាយទៅជាព្រាយបិសាចគឺមិនចម្លែកទេ ប៉ុន្តែឲ្យនាងធ្វើម៉េចទៅចំពោះមុខហេតុការណ៍របៀបនេះ តើអាចរស់នៅកើតទេបើនៅក្នុងផ្ទះមានព្រាយបិសាចនៅជាមួយយ៉ាងដូច្នេះ?

ភីណាងាកមករកនេត្រដោយទឹកមុខច្របូកច្របល់អាការប្រៀបបីដូចជាមិននឹងនសោះ៖

-បងថ្លៃខ្ញុំគាត់ស្លាប់ ខ្ញុំដឹងតាំងពីដំបូងមកម្ល៉េះ ប៉ុន្តែពេលនិយាយទៅអ្នកក្នុងផ្ទះគ្មានអ្នកណាជឿសោះ ឥឡូវនេះមានរឿងធំហើយឲ្យខ្ញុំធ្វើម៉េចទៅ? ឲ្យខ្ញុំធ្វើម៉េចទៅ ជួយគិតខ្ញុំផង! នេត្រ! ឯងនិយាយប្រាប់ខ្ញុំមក! ខ្ញុំខ្លាចណាស់! ខ្ញុំខ្លាចមែន!

ភីណាទ្រេតក្បាលលើស្មានាងក្រមុំនិស្សិតទាំងយំខ្សឹកខ្សួល នារីនិស្សិតប្រកបដោយទឹកមុខខ្វល់ខ្វាយ នាងពោលតប៖

-ខ្ញុំក៏ខ្លាចដែរ ឯងឈប់យំសិនទៅ ឯងយំអញ្ចឹងដោះស្រាយអីកើត?

ភីណាទ្រោបក្បាលដដែលទាំងច្របូកច្របល់ចិត្ត ខណៈនោះសំណាងបើកទ្វារបន្ទប់ទឹកដើរចេញមក ដោយពោលមកកាន់បងស្រីតិចៗ៖

-បង! ជិតភ្លឺហើយ តិចប៉ាគាត់ជ្រាបថាយើងចេញពីផ្ទះ យើងទៅវិញសិនទៅអ្ហីបង?

នេត្រងើបមុខសម្លឹងនាឡិកាប៉ោលលើជញ្ជាំងដោយទឹកមុខបារម្ភ ក៏ស្រាប់តែភ្លាមនោះ ភីណាលូកដៃតោងនេត្រយ៉ាងជាប់ដោយមាត់ពោលឃាត់ញាប់ស្មេរ៖

-កុំទៅ ឯងកុំទៅណ៎ានេត្រ កុំ.....ទៅចោលខ្ញុំ ខ្ញុំមិននៅម្នាក់ឯងទេ ខ្ញុំខ្លាច ខ្ញុំខ្លាចណាស់ ខ្ញុំខ្លាចខ្លាំងណាស់ ផ្ទះនេះមានខ្មោច! ខ្ញុំមុខតែមិនបានសុខទេ ឯងកុំទៅណ៎ា កុំទៅចោលខ្ញុំ!

នេត្រដកដង្ហើមធំ ថ្វីត្បិតនាងកំពុងត្រូវភាពភ័យខ្លាចសង្កត់សង្កិនក្នុងចិត្តក៏ពិតមែន ប៉ុន្តែនៅចំពោះមុខស្ថានភាពបែបនេះបើមិនប្រឹងទប់លំនឹងចិត្តទេ តើធ្វើម៉េចអាចទប់ទល់បាន នាងពោលពន្យល់ភីណា៖

-លែងអីហើយ! បើស្រីព្រាយនោះវាចង់ធ្វើបាបឯង វាច្បាស់ជាធ្វើយូរណាស់មកហើយ ឯងសម្ញុំធ្វើដូចធម្មតាមិនដឹងរឿងអីសោះទៅ!

ភីណាងើបមុខសម្លឹងនេត្រដោយទឹកមុខរបៀបអង្វរករ៖

-តែឯង ឯងកុំទៅចោលខ្ញុំអីនេត្រ! ខ្ញុំមិនទុកចិត្តទេ ខ្ញុំខ្លាច ខ្ញុំខ្លាចណាស់ ខ្ញុំមុខជាទ្រាំមិនបានទេ!

នេត្រមិនទាន់បានឆ្លើយថាយ៉ាងណាតបមកកាន់តរុណីម្ចាស់បន្ទប់នៅឡើយទេ! ជិតដល់ពេលប៉ាក្រោកហើយ គាត់មិនឃើញបងនេត្រនិងខ្ញុំនៅផ្ទះទេ មុខជាមានរឿងធំហើយ!

ភីណាចងចិញ្ចើមដោយខ្វល់ខ្វាយ ខណៈដែលនេត្រឧទានបន្តបន្ថែមលើសម្តីប្អូន៖

-មែនហើយភីណាអ្ហ៎ា ខ្ញុំថាលបចូលមកមើលម្តងទៀតនេះនឹងត្រឡប់ទៅវិញភ្លាម ប៉ុន្តែឃើញឯងសន្លប់ ខ្ញុំគ្រាឯងឡើងមកនេះ ហើយចាំឯងដឹងខ្លួនទើបបានហួសដល់ថ្មើរណេះ បើខ្ញុំមិនត្រឡប់ទៅវិញទេមុខជាវីវរហើយ!

ភីណាកាន់តែព្រួយបារម្ភខ្លាំងជាងមុន នាងពោលសួរវិញភ្លាមទាំងអន្ទះសា៖

-ចុះខ្ញុំ ខ្ញុំគិតយ៉ាងម៉េច?

នេត្រប្រឹងលួងចិត្តភីណាទាំងខ្វល់ខ្វាយ៖

-មិនអីទេ! សម្ញុំគេងទៅអត់អីទេ! ជឿខ្ញុំចុះ គេងទៅណ៎ា!

នេត្របង្ហាញក្ដីស្អុតស្អាញលើផ្ទៃមុខ នាងពោលមកកាន់ភីណា៖

-កុំអ៊ីចឹងអីភីណា! ទប់ចិត្តទៅបានទេ? ណាមួយបន្ទប់បងប្រុសឯងនៅក្បែរនេះស្រាប់ វាមិនហ៊ានធ្វើអីឯងទេ! ស្ដាប់ខ្ញុំណ៎ា! មានការអីក៏ដោយស្អែកយើងពិគ្រោះគ្នា ប៉ុន្តែពេលនេះខ្ញុំត្រូវត្រឡប់ទៅវិញសិនហើយ ទប់ចិត្តឲ្យល្អណា!

នេត្រក្រោកសន្សឹមៗចេញពីគ្រែ ភីណាតាមសម្លឹងនេត្រដោយទឹកមុខមិនស្កប់ចិត្ត នាងឧទានសួរតិចៗទាំងសូរសព្ទនៅញ័ររន្ធត់មិនទាន់នឹងននៅឡើយ៖

-នេត្រ នេត្រ ឯងទៅមែនអ្ហេស៎? ឯងទៅចោលខ្ញុំមែនអ្ហេស៎?

នេត្រដកដង្ហើមធំ ជ្រួញចិញ្ចើម ពោលសួរដោយអាការមិនសប្បាយចិត្ត៖

-ខ្ញុំមិនខ្លាចផង ឯងខ្លាចធ្វើអី? ជិតភ្លឺហើយណ៎ា! ស្រីព្រាយនោះវាខ្លាចឯងជាងឯងខ្លាចវាផងក៏មិនដឹង ឯងប្រឹងទប់ចិត្តឲ្យល្អបន្តិចទៅណ៎ា! ខ្ញុំត្រូវត្រឡប់ទៅវិញសិនហើយ ព្រឹកនេះប៉ាចេញទៅធ្វើការបាត់ ខ្ញុំមុខជាឆ្លងមករកឯងមិនខានទេ!

ភីណាងក់ក្បាលផ្ងក់ៗទាំងភាពភ័យខ្លាចមិនទាន់រលាយបាត់ពីផ្ទៃមុខនៅឡើយ នាងពោលសួរដាច់ៗដោយចិត្តមិនទាន់ទប់បាននឹងនស្រួលបួលនៅឡើយ៖

-ឯងថាមែនអ្ហេស! ឯងមករកខ្ញុំឆាប់ៗណ៎ា!

នេត្រងក់ក្បាលឈោងយកភួយដណ្ដប់ឲ្យភីណា ដោយមាត់ពោល៖

-ដណ្ដប់ភួយទៅ ហើយសម្ងំគេងដូចគ្មានរឿងអីទៅចុះណ៎ា!

ភីណាធ្មេចភ្នែកឱបដៃក្នុងភួយដោយអារម្មណ៍ភ័យខ្លាចនៅមិនទាន់រសាយបានបន្តិចណានៅឡើយទេ នេត្រប្អូនប្រញាប់ប្រញាល់ដើរចេញទៅ ទាំងទាញទ្វារបន្ទប់បិទមកឲ្យភីណាវិញដោយស្រួលបួលផង។

នាងក្រមុំភីណាឱបដៃសម្ងំស្ងៀមកណ្ដាលបរិយាកាសស្ងាត់ច្រៀប នាងចេះតែមានអារម្មណ៍ព្រឺសម្បុរខ្វាកៗ ដោយចេះតែស្រមៃថាស្រីព្រាយនោះកំពុងដើរចូលមកជិតខ្លួន។ ពេលវេលាបានអូសបន្លាយទៅមុខយ៉ាងយឺតយ៉ាវណាស់ ទម្រាំដល់នាឡិកាប៉ោលវាយសាជាថ្មីជាសញ្ញាថាម៉ោង៥ឈានចូលមកដល់ហើយ ភីណាដឹងអស់ហើយ ម្ល៉ោះហើយមាណវីស្ទុះក្រោកពីគ្រែ

យ៉ាងរហ័ស បម្រុងដើរមកបើកទ្វារនឹងអាលរត់ចុះទៅខាងក្រោម ប៉ុន្តែជើងហៀបនឹងឈាន មកដល់មាត់ទ្វារបន្ទប់ ស្រាប់តែពីក្នុងចិត្តផុសចេញមកភ្លាមនូវអារម្មណ៍មិនទុកចិត្តមួយ នាងនឹកដល់ស្ថានភាពស្ងាត់ជ្រងំឯក្រៅបន្ទប់ ពីនេះទៅដល់មាត់ជណ្តើរ ពីជណ្តើរចុះទៅដល់ជាន់ក្រោមគឺមិនមែនជិតត្រឹមតែពីរបីជំហានតែប៉ុណ្ណោះនោះទេ ចុះបើចេញខ្មោចនោះបង្ហាញខ្លួននឹងត្រូវគិតយ៉ាងម៉េចទៅ?

គិតឃើញយ៉ាងនោះភ្លាម នាងក្រមុំភីណាថយក្រោយក្រាកៗ មកលើគ្រែវិញភ្លាមមួយរំពេច នាងឈរផ្អែកជញ្ជាំងដោយជ្រួលច្រាលក្នុងចិត្ត នាងនឹកដល់ឈាមសាច់ក្នុងខណៈដែលវាកំពុងឈ្ងោកមុខបរិភោគសាច់ឆៅនោះ នាងត្រិះរិះដោយព្រឺសាច់ ស្រីបិសាចនោះ វាយកសាច់ឆៅជាអាហារ នរណាហ៊ានធានាថាវាមិនបរិភោគសាច់មនុស្សនោះ? ចុះបើវាបញ្ចេញចង្កូមដូចក្នុងភាពយន្តបរទេស តើគិតយ៉ាងម៉េចទៅ? មិនជឿក៏មិនកើតដែរបើខ្លួនបានឃើញស្រីបិសាចនោះបរិភោគសាច់ស្រស់ដោយផ្ទាល់ភ្នែកទៅហើយនោះ! កាន់តែគិត រឹតតែបារម្ភ នាងងាកឆ្វេងស្តាំដោយអន្ទះសា មិនដឹងថាស្រីបិសាចនោះវាដឹងខ្លួនថានាងបានឃើញអាថ៌កំបាំងរបស់វាដែរឬអត់?

ភ្លាមនោះភ្នែកវាត់ប្រទះទៅនឹងទូរសព្ទដៃដែលបញ្ឈរចោលលើកូនតុក្បែរដំណេកស្រស់ស្រីស្ទុះរឹងលូកយកទូរសព្ទមកចុចទៅរកអ្នកកំលោះម្ចាស់ចិត្តទាំងអារម្មណ៍មិននឹងនះ

-អាឡូ! វិទូ? បងកំពុងធ្វើអ្វី?

សំឡេងអ្នកកំលោះគូដណ្តឹងតបមកវិញពីចុងម្ខាងដោយអាការភ្ញាក់ផ្អើលៈ

-ភីណា? មានរឿងអ្វី?

តាមមើលបណ្តាលមកពីនាងក្រមុំទូរសព្ទទៅរកគេក្នុងពេលថ្មើរណេះ ចម្លែកខុសពីធម្មតាអញ្ចឹងហើយទើបធ្វើឲ្យវិទូឆ្លើយតបមកវិញក្នុងអាការភ្ញាក់ផ្អើលយ៉ាងនេះ នាងក្រមុំអស់ពីស្លន់ស្លោ នាងទៅជាយំអណ្តឹតអណ្តក នាងតបទៅកាន់អ្នកកំលោះដែលកំពុងស្តាប់ឯចុងម្ខាងដោយសូរសព្ទខ្សឹកខ្សួលៈ

-វិទូអ្ហា! បងមកភ្លាមបានទេ? អូន អូន ខ្លាចណាស់ អូនខ្លាចណាស់!

សូរសព្ទអ្នកកំលោះគូស្នេហ៍លាន់មកពីចុងម្ខាងវិញដោយអាការងឿងឆ្ងល់ និងខ្វល់ខ្វាយៈ

-ភីណា! មានរឿងអីកើតឡើង? កុំយំ និយាយប្រាប់ឲ្យស្រួលមក ប្រាប់បងមក! ផ្ទះមានរឿងអីមែនទេ? ភីណា!

ស្រស់ស្រីខំទប់ចិត្តកុំឲ្យជ្រួលច្របល់ពេក ប៉ុន្តែសូរសព្ទរបស់នាងដែលឮទៅដល់វិទូគឺនៅតែខ្សឹកខ្សួលរអាក់រអួលដដែល៖

-បងមកភ្លាមណ៎ា! អូននៅចាំ!

វិទូទំនងជានឹកគិតដល់រឿងអកុសលណាមួយថាអាចនឹងកើតមានចំពោះស្រីស្រស់របស់អ្នកហើយបានជានាងមានអាការបែបនេះ ប្រញាប់ប្រញាល់ពីចុងម្ខាងមកកាន់ភីណា៖

-បាន!.....ចាំបងណ៎ា! បងទៅភ្លាម ទប់ចិត្តឲ្យបានស្រួល! បងទៅដល់ឥឡូវហើយ!

នាងក្រមុំបិទទូរសព្ទដោយថយមកអង្គុយលើគ្រែវិញ ប៉ុន្តែភ្នែកក្រឡេកឆ្វេងស្តាំ ឯបេះដូងក៏កំពុងលោតញាប់មិនទាន់បាត់នៅឡើយទេ។ ភីណាឱនសម្លឹងសំលៀកបំពាក់ខ្លួនឯង នាងស្ទុះក្រោកបើកទូសំលៀកបំពាក់ខោអាវមកផ្លាស់ លុបលាងមុខមាត់ក្នុងបន្ទប់ទឹក ចិត្តមួយបន់យ៉ាងណាឲ្យតែវិទូមកដល់ឲ្យបានឆាប់ប៉ុណ្ណោះ។

កំពុងឈរសិតសក់មុខកញ្ចក់ទាំងអារម្មណ៍ព្រួយបារម្ភ ក៏ស្រាប់តែត្រចៀកឮសូរគោះទ្វារបន្ទប់លាន់តុកៗ ភីណាស្រវាដើរតម្រង់ទៅកាន់ទ្វារដោយចិត្តរីករាយ ព្រោះនឹកថាប្រហែលជាវិទូមកដល់នៅខាងក្រោមហើយអ្នកបម្រើឡើងមកគោះទ្វារប្រាប់ហើយមើលទៅ ប៉ុន្តែទ្វារទើបតែរបើកកាលណា ភីណាត្រូវភ្ញាក់ស្ទើរតែគាំងបេះដូងដួលសន្លប់ ត្បិតអីពីក្រោយទ្វារដែលកំពុងរបើកសន្សឹមៗនោះពុំមានស្រមោលអ្នកណាម្នាក់សោះ ក្នុងគ្រាប្រថុចញ៉ុចបែបនេះវិធីដំបូងបង្អស់ដែលតរុណីយើងរើសយកមកប្រើគឺស្ទុះចេញទៅក្រៅអើតមើលឆ្វេងស្តាំយ៉ាងរហ័សបំផុត ប៉ុន្តែពិតជាផ្ទុយស្រលះពីការគិតឃើញរបស់នាងមែន ខាងក្រៅបន្ទប់ពិតជាមិនឃើញមានស្រមោលមនុស្សម្នាក់ទាល់តែសោះ។ ភីណាធ្លាក់ថ្លើមគ្មុកកណ្តាលបរិយាកាសស្ងាត់ច្រៀប ដែលទ្វារបន្ទប់នានាជុំវិញនេះសុទ្ធសឹងបិទជិតសូន្យទាំងអស់ នាងក្រមុំទទួលអារម្មណ៍ថាភ័យរន្ធត់ណាស់ នាងស្ទុះចូលមកក្នុងបន្ទប់វិញយ៉ាងរហ័ស។

នាងលើកដៃស្ទាបទ្រូងដែលកំពុងលោតស្ទើរធ្លាយបេះដូងចេញមកក្រៅ ដោយបែរមុខដើរចូលពីការគិតស្មានមួយបានប្រាកដឡើងនៅចំពោះនាងក្រមុំតែម្ដង ដែលស្ទើរតែធ្វើឲ្យនាងទន់ជង្គង់ដួល។

ភីណាបើកភ្នែកក្រឡេតទៅរូបរាងនារីបងថ្លៃខ្លួនដែលកំពុងឈរផ្ទឹងកណ្ដាលបន្ទប់ សើចពព្រាយសម្លឹងមក គឺបបូរមាត់ដែលគាត់កំពុងញញឹមនេះហើយ កាលពីយប់ខ្លួនបានឃើញគាត់ប្រឡាក់ទៅដោយឈាមសត្វប្រតាកពេញគួរឲ្យតក់ស្លុត។ ភីណាអស់ពីសម្លឹងទៅស្នាមញញឹមដែលគួរឲ្យព្រឺព្រួចនោះហើយ នាងបែរជាងាកក្រោយស្ទុះរត់យ៉ាងលឿនតម្រង់ទ្វារនឹងអាលចាកចេញទៅក្រៅបន្ទប់ឲ្យបានឆាប់ ប៉ុន្តែខណៈនោះមិនដឹងជាមានកម្លាំងខ្យល់បក់មកពីណាទេ រុញទ្វារបន្ទប់នាងក្រមុំឲ្យបិទគ្រឹបជាប់ទៅវិញយ៉ាងរហ័សជាងកាយវិការរបស់ភីណាទៅទៀត ទោះបីជានាងក្រមុំប្រឹងទាញបើកយ៉ាងណាក៏ទ្វារនៅតែជាប់ម៉ឺងដដែល។

សភាពរន្ធត់ញាប់ញ័រកំពុងគ្រប់ដណ្ដប់លើដួងព្រលឹងមាណវីយើង ក៏ក្នុងពេលនោះដែរដែលសោតាទាំងគូបានឮសូរសំណើចគួរឲ្យតក់ស្លុតលាន់ខ្ទរផ្ទៃបន្ទប់ ភីណាបែរមកវិញផ្ដោតភ្នែកសម្លឹងទៅលើផ្ទៃមុខជាំខ្មៅរបស់នារី មិនមែនមនុស្សដែលកំពុងសើចលាន់ខ្ទរផ្ទៃបន្ទប់ បង្កើតជាសូរសព្ទគួរឲ្យព្រឺក្បាល ភីណាផ្អែកខ្នងជាប់ទៅនឹងទ្វារបន្ទប់ ដោយទឹកមុខស្លេកស្លាំងគ្មានឈាមមួយតំណក់ នាងពោលទម្រាំនឹងចេញសំឡេងបានមួយម៉ាត់ៗ៖

-ស្រីបិសាច!..... ឯង!..... ឯងចង់ធ្វើអីយើង?

ខ្មោចឆៅនេះមិនមានចេញស្ដីអ្វីតបមកវិញសោះ ប៉ុន្តែដៃទាំងពីររបស់គេដែលកំពុងលូកវែងសំដៅមកភីណា ក៏ល្មមឲ្យមាណវីយើងភិតភ័យស្ទើរលោះព្រលឹងដែរ នាងក្រមុំសែនតក់ស្លុតនាងស្ទុះគេចចេញដួលទ្រោបទៅលើកូនតុសរសេរដែលនៅក្បែរនោះ ចានផ្លែឈើកំពុងនៅជ្រងោទីនោះដែរ ឥតគិតច្រើននាងក្រមុំលូកដៃចាប់យកកាំបិតមកក្ដាប់យ៉ាងណែនបែរក្រោយយ៉ាងរហ័ស ចាក់សំដៅទៅកាន់ដៃទាំងគូរបស់ "ជនមិនមែនមនុស្ស" ដែលកំពុងលូកសំដៅមក។

## ភាគទី១២

កូនកាំបិតដ៏មុតស្រួចចាក់ជ្រុចមុតយ៉ាងជ្រៅជាប់ឆ្អឹតទៅនឹងកំភួនដៃស្ដាំរបស់ "ខ្មោចឆៅ" ប៉ុន្តែចម្លែកបំផុតគឺថាវានៅឈរស្ងៀមដដែលមិនមានបង្ហាញភាពឈឺចុកចាប់បន្តិចណាទាល់

តែសោះ ណាមួយមិនមានឈាមមួយតំណក់ណាស្រក់ចេញមកឡើយ។ ហេតុការណ៍ផ្ទុយស្រឡះពីភាពប្រក្រតីបែបនេះ រឹតតែបង្កនូវអារម្មណ៍ពុះកញ្ជ្រោលលាយដោយក្ដីភ័យតក់ស្លុតក្នុងចិត្តមាណវីភីណា ថែមឡើងមួយកម្រិតទៀតនាងថយក្រោយក្រាកៗ រហូតទាល់តែទល់ទៅប៉ះនឹងជញ្ជាំងបន្ទប់ដោយភ្នែកនៅតែបើកក្រឡេតសម្លឹងទៅ "ខ្មោចចម្លែក" ដែលកំពុងលូកដៃឆ្វេងទាញដកកូនកាំបិតចេញពីកំភួនដៃស្ដាំធ្វើព្រងើយ ដោយគ្មានបន្សល់នូវស្លាកស្នាមរបួស ឬឈាមមួយតំណក់ទាល់តែសោះ។

សេចក្ដីតក់ស្លុតក្នុងពេលនេះ ទោះជារៀបរាប់យ៉ាងណាក៏មិនអស់សេចក្ដីដែរ នាងក្រមុំក្ដាប់ដៃទាំងចិត្តរន្ធត់ហារមាត់ស្រែកភ្លាត់សំឡេង៖

-ជួយផង! ខ្មោច!

ខ្មោចឆៅងើបមុខបើកភ្នែកធំៗ សម្លក់ថ្មៃមកកាន់ភីណា នាងក្រមុំមិនអាចទប់ទល់ជាមួយក្ដីរន្ធត់ញាប់ញ័របានតទៅទៀតឡើយ នាងទន់ជើងអង្គុយឱបក្បាលស្រែករហូត ស្រែកទាល់តែភ្លាត់សំឡេង ក៏ក្នុងពេលជាមួយគ្នានេះដែរ នាងគ្មានសេចក្ដីសង្ឃឹមថាអាចគេចផុតពីក្រញាំខ្មោចឆៅគ្មានព្រលឹងនោះទេ ដោយគិតតែពីស្រែក ស្រែករហូតស្ទើរតែលែងចេញសំឡេងទម្រាំឮសូរស្នូរជើងមនុស្សរត់ញាប់រន្ថើនឡើងមក ជាមួយនឹងសន្ទឹកច្រានទម្លាយទ្វារចូលមកយ៉ាងខ្លាំងក្លា។ ឈរបើកមកក្នុងយ៉ាងរហ័ស មាណវីយើងអរកកើតក្នុងចិត្ត នាងងើបមុខសម្លឹងទៅបងប្រុសខ្លួនដែលកំពុងសម្រុកចូលមកដោយទឹកមុខភ័ន្តភាំង បន្ទាប់មកវិទូក៏ស្ទុះចូលមកយ៉ាងលឿនតាមពីក្រោយដែរ។

ភីណាស្រវាក្រោកយ៉ាងរហ័សមកពួនពីក្រោយខ្នងបងប្រុសទាំងដៃជើងញ័រចំប្រប់ សំឡេងលោកកុសលសួរញាប់ស្មេរដោយអាការភ្ញាក់ផ្អើលនឹងងឿងឆ្ងល់៖

-មានរឿងអ្វី? មានរឿងអ្វីហ្នឹង?

ក្រមុំភីណាឈរញ័រទទ្រើកពីក្រោយស្មាបងប្រុស អារម្មណ៍រន្ធត់ញាប់ញ័រទើបតែមួយប៉ប្រិចភ្នែកអញ្ចឹងតើធ្វើម៉េចរំងាប់បានភ្លាមទៅ? នាងនៅឈរដោយភ័យខ្លាចក្រោយស្មាបងប្រុសដោយមិនទាន់ហាឆ្លើយតបមួយម៉ាត់ណាឲ្យរួចចេញមកសោះ ខណៈនោះដែរសំឡេងវិទូពោលសួរវិញម្ដង ដោយអាការឈឺឆ្អាល៖

-ភីណា! មានរឿងអី? ម៉េចក៏ស្រែកខ្លាំងម្ល៉េះ?

អ្នកបម្រើទាំងបីនាក់ក៏ស្ទុះឡើងមកដល់បន្ទាប់គ្នាឈរផ្តុំពេញមុខទ្វារបន្ទប់ដែរ ភីណាហាក់នឹងនចិត្តជាងមុនបន្តិច នាងពោលតបដោយផ្តោតភ្នែកសម្លឹងទៅ "បងថ្លៃមិនមែនមនុស្ស" របស់ខ្លួនទាំងភ័យខ្លាចៈ

-ខ្មោច! ខ្មោច! វា.....វាចង់សម្លាប់ខ្ញុំ.....ស្រី.....ស្រីខ្មោច ស្រីនោះជាខ្មោចទេ វាជាខ្មោច!

នាងក្រមុំស្រែកបណ្តើរយំបណ្តើរ ដៃមួយលើកចង្អុលតម្រង់ទៅបងថ្លៃស្រីដែលកំពុងឈរធ្មឹងកណ្តាលបន្ទប់ផង។ អ្នកទាំងអស់ហាក់ដូចជាមានការភ្ញាក់ផ្អើលចំពោះអាការស្រស់ស្រីណាស់ ពួកគេសម្លឹងនាងរួចដៀងភ្នែកសម្លឹងទៅអ្នកស្រីវ័យក្មេងដោយក្តីងឿងឆ្ងល់ ព្រោះតែបានស្តាប់ឮសម្តីប្រកបដោយភាពភិតភ័យរបស់នាងក្រមុំភីណា ខណៈនោះដែរសំឡេងលោកកុសលបន្លឺមកកាន់ប្អូនស្រីរបៀបមិនសប្បាយចិត្តៈ

-អូនឯងកំពុងធ្វើអីហ្នឹងភីណា? អូនឯងនិយាយសម្តីរបៀបគ្មានសតិអញ្ចឹងទៅកាន់អ្នកបងឯងអ្ហែស៎?

ភីណាណាមួយហួងណាមួយភិតភ័យមិនទាន់បាត់ នាងប្រញាប់បន្លឺតបទៅកាន់បងប្រុសភ្លាមៈ

-ប្រពន្ធរបស់បង គឺជាខ្មោចទេ វាជាខ្មោចពិតមែន!

លោកកុសលចងចិញ្ចើមសឹងដល់គ្នា សម្លឹងមកប្អូនស្រីនាងក្រមុំខំប្រឹងពោលពន្យល់បងប្រុសបន្ថែម ទាំងសម្លឹងមុខគាត់មិនដាក់ភ្នែកៈ

-បង! បងជឿខ្ញុំទៅ ស្រីនេះសាហាវណាស់ វាជាខ្មោច វាមិនមែនមនុស្សទេ មិនមែនមនុស្សទេ!

បងប្រុសភីណាបង្ហាញសេចក្តីមួហួងលើផ្ទៃមុខ គាត់សម្លឹងប្អូនអស់ចិត្តរួចងាកមករកភរិយាម្តង ហាក់ដូចជាមានបំណងចង់សួរថា តើរឿងហេតុយ៉ាងណាខ្លះ ក៏ស្រាប់តែភ្លាមនោះ អ្នកស្រីវ័យក្មេងបង្ហាញទឹកមុខរបៀបមិនស្រួលចិត្តនិយាយមកកាន់ស្វាមីៈ

-បង! ម៉េចក៏ប្អូនយើងក្លាយជាអញ្ចឹង?

ក្នុងខណៈភីណាខឹងស្ទើរស្រក់ឈាមតាមភ្នែក នារីនោះប្ដូរសំឡេងទៅជាអណ្ដឺតអណ្ដក ហើយពោលប្រាប់ប្ដីបន្ថែមដោយទឹកមុខស្លូតបូត៖

-អូនចូលមកប្រុងសួរភីណាថាអាចទៅរៀនបានវិញឬនៅ មិនដឹងថាឃើញមុខអូនកាលណា ប្អូនទៅជាស្រែកខ្លាំងៗឮដល់គ្រប់គ្នា! ហើយឥឡូវទៅជានិយាយសម្ដីផ្ដេសផ្ដាសមិនដឹងរឿង គ្មានក្បាលកន្ទុយទៀត ខ្ញុំអត់យល់សោះទេនៀក!

ភីណាបើកភ្នែកធំៗកាលបើឃើញស្ត្រី "មិនមែនមនុស្ស" រូបនេះ ប្រែក្រឡាស់និយាយខុសពីការពិតនៅចំពោះមុខគេរាល់គ្នាបែបនេះ នាងក្រមុំចងចិញ្ចើមដោយក្រេវក្រោធ នាងស្រែកកាត់ទាំងកំហឹង៖

-ស្រីចង្រៃ! ស្រីបិសាច ! និយាយតែពាក្យកុហក!

ភីណាងាកមករកបងប្រុស នាងងាកមកសម្លឹងគាត់ក៏ឃើញគាត់កំពុងបង្ហាញឫកពាមិនសប្បាយចិត្តមើលមកខ្លួនវិញ។ នាងកើតជ្រួលច្របល់ថាតើអីទៅអាចធ្វើឲ្យគាត់លែងយកចិត្តទុកដាក់នឹងសម្ដីប្អូនសោះយ៉ាងនេះ? នាងប្ដូរទិសដៅបែរមករកកំលោះគូដណ្ដឹង និងអ្នកបម្រើបីរូបដែលកំពុងឈរពីក្រោយខ្នង ដោយប្រឹងពោលពន្យល់ប្រាប់ពួកគេ៖

-បងវិទូ! មីងអួន មីងម៉ាប់ ពូសួស.....អ្នកទាំងអស់ជឿខ្ញុំទៅ! ស្រីនោះជាខ្មោច មិនមែនជាមនុស្សទេ! មិនមែនជាមនុស្សធម្មតាទេ! អ្នកទាំងអស់ដឹងទេ យប់មិញខ្ញុំឃើញវាចូលទៅក្នុងបន្ទប់បាយ លួចហូបសាច់ឆៅក្នុងទូទឹកកក ឈាមប្រឡាក់ពេញមាត់ គួរឲ្យខ្ពើម...គួរឲ្យខ្លាចណាស់។ អ្នកទាំងអស់គ្នាត្រូវជឿខ្ញុំ ស្រីនេះជាខ្មោចទេ...ជាខ្មោចពិតមែន!

អ្នកទាំងអស់ងាកសម្លឹងទៅកាន់អ្នកស្រីវ័យក្មេងព្រមៗគ្នា សំឡេងអ្នកអួនពោលសួរមកកាន់ភីណាដោយអាការសង្ស័យ៖

-នាងតូច! អញ្ចឹង សាច់គោឆៅ ដែល.....ដែល! ចេះតែបាត់ពីទូនោះ គឺ...គឺ!...???

នាងក្រមុំងក់ក្បាលញាប់ស្មេរហើយឆ្លើយតបយ៉ាងរហ័ស៖

-ត្រូវ! សាច់ឆៅដែលចេះតែបាត់មិនដឹងហេតុ ក៏សុទ្ធតែត្រូវនាងបិសាចនេះ លួចមែន! វាជាខ្មោច វាជាខ្មោចណ៎ា អ្នក!...។

នាងក្រមុំមិនទាន់បាននិយាយចប់ស្រួលបួលផង លោកកុសលជាបងស្រែកកាត់ដោយអាការក្រោធខឹង៖

-បានហើយ!.....អូនឯងផ្ដេសផ្ដាសដល់ណាទៀត? និយាយសម្ដីដូចមនុស្សមិនគ្រប់ដប់អញ្ចឹងកើតដែរអ្អេស៎ភីណា?

ភីណាហាក់ភ័ន្តភាំងនឹងអាកប្បកិរិយារបស់បងប្រុស។ នាងក្រមុំរេសម្លឹងទៅបងថ្លៃ "បិសាច" របស់ខ្លួនដែលកំពុងដើរមួយៗចូលទៅក្បែរស្វាមី។ ស្ត្រី "មិនមែនមនុស្ស" រូបនោះចូលកាន់តែកៀក ភីណារឹតតែបើកភ្នែកធំៗសម្លឹងទៅ នាងឃើញស្រីដែលខ្លួនយល់ថាជាខ្មោចឆៅនោះកំពុងក្លែងបន្លំធ្វើទឹកមុខស្លូតបូតនិយាយមួយៗទៅរកប្ដី៖

-កុំខឹងពេកបង! តាមមើលជំងឺភីណាមិនទាន់ជាស្រួលបួលតែប៉ុណ្ណឹង! បើពេទ្យមើលមិនកើតយើងទៅរកគ្រូខ្មែរម្ដង!

ភីណាចងចិញ្ចើម នាងអស់ពីក្រេវក្រោធក៏ទៅជាហួសចិត្ត មិននឹកស្មានថាស្រីបិសាចនេះក៏ចេះមានកលល្បិចនិយាយបោកប្រាស់ភ្នែកគេបានយ៉ាងល្អទៀត តាមមើលលើកនេះចង់ពន្យល់ឲ្យបងប្រុសខ្លួនយល់មុខតែពិបាកហើយ។

ខណៈនោះនាងដៀងភ្នែកសម្លឹងទៅកូនកាំបិតចិតផ្លែឈើដែលកំពុងដេកស្ងៀមលើតុឌួនៅឡើយ នាងនឹកដល់កាយវិការរបស់ស្រីព្រាយនោះ នៅពេលដែលគេគ្រប់គ្នាមិនទាន់ឡើងមកដល់។ តរុណីពោលដោយទឹកមុខខ្វល់ខ្វាយ៖

-ស្រីបិសាចឈប់ធ្វើពើទៀតទៅ!

វិទូដែលឈរក្បែរក្រមុំគូស្នេហ៍ គេពោលតិចៗមកកាន់ភីណាដោយក្ដីបារម្ភ៖

-ភីណាអូ៎ា! ទប់ចិត្តបន្តិចសិនមើល៍! ពាក្យអញ្ចឹងៗនិយាយច្រើនខុសច្រើនទេ! ដឹងអត់?

តរុណីងាកមករកអ្នកកំលោះភ្លាម នាងពោលតបទៅកាន់នាយទាំងចងចិញ្ចើមសឹងដល់គ្នា៖

-បងទូក៏អត់ជឿខ្ញុំដែរ? អម្បាញ់មិញពេលអ្នកទាំងអស់គ្នាមិនទាន់ឡើងមក ស្រីនេះលូកដៃប្រុងច្របាច់កខ្ញុំ!.....ខ្ញុំភ័យពេកស្រវាបានកូនកាំបិតចាក់ដៃវាយ៉ាងខ្លាំង កាំបិតមុតធ្លាយកំភួន

ដៃវាទៅហើយ ប៉ុន្តែវាអត់ឈឺសោះ ដកកាំបិតចេញវិញធ្វើព្រងើយ...ហើយ....ហើយ...ឈាមមួយតំណក់ក៏មិនឃើញស្រក់ផង! បងឯងដឹងអត់?

ទាំងអស់គ្នាភ្នែកសម្លឹងទៅកូនកាំបិតចិតផ្លែឈើ ដែលកំពុងដេកស្ងៀមលើកម្រាលឥដ្ឋ រួចនាំគ្នាដៀងភ្នែកសម្លឹងទៅ "ខ្មោចឆៅ" នោះមិនដាក់ភ្នែកដែរ។ ភ្លាមនោះនាងឃើញបងថ្លៃខ្មោចរបស់ខ្លួនកំពុងប្រឹងធ្វើទឹកមុខរបៀបធ្លាក់ទឹកចិត្ត ហើយនិយាយប្រកែកដោយស្ទាត់ជំនាញ៖

-ភីណា! នៅសុខៗម៉េចក៏ប្រឌិតរឿងមកផ្តេសផ្តាសម្លឹងៗ? ខឹងបងរឿងអី? បងធ្វើអ្វីឲ្យយើងទាស់ចិត្ត? និយាយមកចុះ! តែកុំនិយាយបំផ្លើសផ្តេសផ្តាសឲ្យអ្នកក្នុងផ្ទះជ្រួលច្របល់!

ភីណាមួហ្មងណាស់ទៅហើយ ប៉ុន្តែនាងនៅមិនទាន់ហាតបថាយ៉ាងណានៅឡើយទេ។ ស្រីដែលគ្មានគេជឿ ងាកសម្លឹងជុំវិញខ្លួនក៏ឃើញថាទឹកមុខមនុស្សក្នុងផ្ទះសម្លឹងមកនាងហាក់សង្ស័យច្រើនជាង។ ដឹងថាមិនត្រូវបណ្តោយឲ្យស្រីបិសាចនេះអាចបន្លប់ពួកគេធ្វើតាមអំពើចិត្តទៀតនោះ នាងគ្មានវិធីអ្វីក្រៅពីស្ទុះរឹងទៅរើសកូនកាំបិតពីលើឥដ្ឋមកក្តាប់យ៉ាងណែនក្នុងដៃ ចាក់សំដៅសាជាថ្មីទៅកាន់អ្នកស្រីវ័យក្មេងទាំងភ្លើងកំហឹងផ្ទុះចេញតាមរយៈវាចាមុតស្រួយ៖

-ផ្តេសផ្តាស មិនផ្តេសផ្តាស គង់តែដឹងទេ!

កាំបិតចាក់យ៉ាងដំណំ តាមសន្ទុះកំហឹងរបស់មាណវីមុតចូលជ្រៅទៅលើកំភួនដៃ ដែលអ្នកស្រីវ័យក្មេងដែលលើករងកាត់ពីមុខកាំបិត ធ្វើឲ្យសូរសម្រែកឈឺចាប់ អូយ! លាន់ចេញពីបបូរមាត់អ្នកស្រីវ័យក្មេង ហើយឈាមក្រហមឆ្អៅ បានស្រក់តក់ៗទៅលើកម្រាលឥដ្ឋ។

ក្នុងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ រកតែអ្នកដទៃឃាត់មិនទាន់ផង នាងក្រមុំភីណាបានធ្វើឲ្យបងថ្លៃមានរបួសស្រេចទៅហើយ គឺនៅចំពោះភ្នែកអ្នករាល់គ្នាស្រស់ៗតែម្តង។ ម្តងណេះមិនមែនភិតភ័យទេ គឺងឿងឆ្ងល់ខ្លាំងសម្បើមណាស់ រហូតទាល់តែនាងពន្លែងកាំបិតពីដៃថយក្រោយក្រាកៗដោយមិនជឿភ្នែកខ្លួនឯង។

ជាក់ស្តែងគឺភីណាមិនអស់ចិត្ត ត្បិតអីកាលលើកទីមួយដែលខ្លួនចាក់ត្រូវកំភួនដៃបងថ្លៃ កុំថាឡើយឈាមហូរ សូម្បីតែសម្រែកឈឺចាប់មួយអ៊ឺះក៏អត់ផង ម៉េចក៏ពេលនេះ?

អារម្មណ៍ទាំងមូលកំពុងវិលវល់ដោយមិនទាន់ដឹងថាត្រូវធ្វើយ៉ាងណាឲ្យសមផង ក៏ស្រាប់តែភ្លាមនោះបងប្រុសដែលប្រកបដោយទឹកមុខក្រេវក្រោធយាដៃបម្រុងទះកំផ្លៀងនាងតាមសន្ទុះនៃកំហឹង។ បើកុំតែវិទូស្ទុះមកជួយទាញនាងចេញ ទាន់ម្ល៉េះសមនាងក្រមុំភីណាស្រស់ប្រិមប្រិយត្រូវមួយកំផ្លៀងកណ្ដាលចំណោមទៅហើយ។

វិទូឈររាំងពីមុខម្ចាស់ចិត្តដោយព្រួយបារម្ភ ចំពោះមុខបញ្ហាដែលកំពុងឈានទៅស្មុគស្មាញឡើងៗ។ ភីណាឈរពីក្រោយអ្នកកំលោះគួដណ្ដឹង.... នាងមិនមែនភ័យទេ ប៉ុន្ដែគឺនាងមិនអស់ចិត្ត ...នាងមិននឹកស្មានថា ...ព្រោះតែកលល្បិចថោកទាបរបស់ស្រីបិសាចនោះ បងប្រុសខ្លួនដាច់ចិត្តលើកដៃទះកំផ្លៀងខ្លួនកណ្ដាលចំណោមយ៉ាងនេះទេ។

ខណៈដែលចិត្តកំពុងក្ដុកក្ដួលនៅឡើយនោះ នាងឮបងប្រុសខ្លួនបន្លឺឡើងដោយកំហឹង៖

-វិទូ! ប្អូនកុំឃាត់បង! បងត្រូវប្រដៅវាផ្ទាល់ដៃ.....វាគ្មានស្គាល់ខុសត្រូវអញ្ចឹង មិនត្រូវបណ្ដោយតាមចិត្តវាទៀតទេ!

នាងក្រមុំសម្លឹងទៅបងប្រុសរបស់ខ្លួនដោយឈឺចិត្ត។ ចំហាយក្ដៅងំជះចេញពីក្រសែភ្នែកទាំងគូ រួមជាមួយនឹងតំណក់ជលនេត្រក្ដៅឧណ្ហៗប្រជែងគ្នាហូរចេញមកជោកលើផែនថ្ពាល់ដែលក្រហមដោយកំហឹង។ នាងស្រវាស្ទុះទៅពីមុខវិទូ ស្រែកដាក់បងប្រុសខ្លួនតាមតែសន្ទុះចិត្តមួយហ្មង៖

-ដើម្បីស្រីព្រាយហ្នឹង បងឯងលើកដៃវាយប្អូនខ្លួនឯង? វាជាស្រីបិសាច ស្រីព្រាយ !

អ្នកបម្រើទាំងឡាយឈ្ងោកមុខដោយភ័យញ័រចំប្រប់នៅពេលបុរសមានអំណាចជាងគេកំពុងឈឺចាប់នឹងមុខរបួសរបស់ភរិយាសំណព្វក្រោមស្នាដៃប្អូនស្រីតែមួយគត់របស់ខ្លួន។ មីងអួនរត់ទៅរកប្រអប់ថ្នាំនាង។ ចំណែកភីណាមិនទាន់បញ្ចប់នូវប្រយោគស្រួលបួលផង ក៏ត្រូវវិទូទាញដៃឲ្យថយក្រោយខ្នងវិញ ប៉ុន្ដែនាងវិញនៅមិនទាន់បញ្ឈប់នៅឡើយ នាងនៅស្រែកខ្លាំងៗទៅកាន់បងប្រុសដែលប្រកបដោយទឹកមុខក្រេវក្រោធ៖

-បងឯងចង់វាយខ្ញុំក៏វាយទៅ ខ្ញុំមិនថាទេ ប៉ុន្ដែស្រីនេះជាបិសាច ខ្ញុំនៅតែនិយាយ វាមិនមែនបងថ្លៃខ្ញុំទេ វាជាបិសាចទេ!

សំឡេងវិទូស្រែកឡើងយ៉ាងខ្លាំងកាត់ផ្ដាច់ប្រយោគតក់ក្រហល់របស់ភីណា៖

-ល្មមៗបានហើយ! ប្រឹងដំឡើងសំឡេងដល់ណាទៀត?

នាងក្រមុំងាកសម្លឹងមុខអ្នកកំលោះគួដណ្ដឹងថ្មី ព្រោះតែក្ដីភ្ញាក់ផ្អើល។ ចំណេងស្នេហ៍គេទាំងពីរបានកកើតផ្សារភ្ជាប់គ្នាច្រើនឆ្នាំកន្លងមកហើយ ប៉ុន្តែនេះគឺជាលើកដំបូងបង្អស់ដែលនាងឃើញគេបង្ហាញអាការមិនសប្បាយចិត្តខ្លាំងថ្នាក់នេះ។

វិទូងាកទៅរកលោកកុសលហើយពោលទម្លាក់សូរសំឡេង៖

-បង! ជូនអ្នកបងទៅមន្ទីរពេទ្យសិនទើបបាន!

ភីណាឃើញបងប្រុសខ្លួនបញ្ចេញអាការអាណិតអាសូរភរិយាដោយម្ទីម្ទាគ្រាអ្នកស្រីបិសាចនោះចាកចេញពីបន្ទប់ដោយប្រញាប់ប្រញាល់ តាមមើលគឺបញ្ជូនទៅមន្ទីរពេទ្យតាមសម្ដីរបស់វិទូហើយ។ តែស្ត្រីមានពុតនោះពោលរារាំងស្រាលៗតាមសំឡេងមាយាស្ត្រី៖

-អត់ទៅណាទេ! រុំរបួសនៅផ្ទះញ៉ាំថ្នាំផ្សះទៅបានហើយ! បើអ្នកក្រៅឃើញ នាំតែគេនាំគ្នានិយាយពីរឿងគ្រួសារយើងអត់អំពើទេ!

ភីណាឈរផ្ទឹងកណ្ដាលបន្ទប់ នាងខឹងស្ទើរស្រក់ឈាមចេញតាមភ្នែក អ្នកបម្រើទាំងបីម្ទីម្ទាថយទៅអស់ដោយរវល់រៀបចំរុំរបួសជូនអ្នកស្រីវ័យក្មេងរបស់ពួកគេ។ ចំណែកវិទូឈរឈ្មោកមុខប្រច់ចង្កេះដោយមិនចេញស្ដី។

គ្រាន់តែឃើញអាការក៏ដឹងថាគេមិនសប្បាយចិត្តដែរ។ ទោះយ៉ាងណាភីណាយល់ថាអ្នកដែលរងគ្រោះអយុត្តិធម៌ជាងគេនៅតែជានាងដដែល អញ្ចឹងហើយទើបនាងស្រែកខ្លាំងៗតែម្នាក់ឯង ព្រោះតែមិនអាចទប់ស្កាត់ការរំជួលចិត្តបាន៖

-ឆ្កួត!...ឆ្កួតណាស់... ឆ្កួតអស់ហើយ! ខ្ញុំនិយាយការពិត អត់អ្នកណាជឿទេ នាំគ្នាជឿតែស្រីបិសាចនោះ!

វិទូងើបមុខដែលរោលរាលទៅដោយភាពមិនស្រួលចិត្ត អ្នកកំលោះសម្លឹងមកកាន់នាងក្រមុំហើយពោលសង្កត់ពាក្យធ្ងន់ៗ៖

-ភីណា? ដឹងថាខ្លួនកំពុងធ្វើអីទេ? ដឹងថាខ្លួនកំពុងដូចស្អីទេ? អូនធ្វើឲ្យផ្ទះច្របូកច្របល់អញ្ចឹងហើយនៅមិនអស់ចិត្តទៀតអ្ហេស៎?

ភីណាងើបមុខដែលពោរពេញទៅដោយក្តីឈឺចិត្ត នាងសម្លឹងមកអ្នកកំលោះគូស្នេហ៍ដោយក្តីមួហ្មង នាងបន្លឺទាំងយំសស្រាក់៖

-ខ្ញុំខុសអ្វេស? បើអញ្ចឹងចេញទៅ ចេញទៅតាមស្រីបិសាចនោះទៅ ឬមួយក៏ចង់បន្ទោសខ្ញុំ ឬមួយក៏ចង់ទះកំផ្លៀងខ្ញុំ ប្រដៅខ្ញុំជំនួសបងកុសល?

វិទូដកដង្ហើមធំដោយប្រឹងរំងាប់កំហឹងទាំងប៉ុន្មានដែលកំពុងកើតមានក្នុងចិត្ត អ្នកកំលោះទម្លាក់សំឡេងបន្លឺមួយទៅកាន់ក្រមុំគូស្នេហ៍៖

-អូនទប់ចិត្តឲ្យនឹងនសិនទៅ មានរឿងអីក៏ដោយ ក៏ត្រូវដោះស្រាយតាមសម្រួលដែរ!

ភីណាចងចិញ្ចើមសម្លឹងមកវិទូ នាងឧទានសួរដោយចុកណែនក្នុងចិត្ត៖

-តែវាជាបិសាច វាចង់ច្របាច់កសម្លាប់ខ្ញុំ អាចដោះស្រាយតាមសម្រួលកើតដែរទេ? អាចទប់ចិត្តកើតទេ?

ដល់វេនវិទូចងចិញ្ចើមម្តង អ្នកកំលោះយល់ថាកាន់តែស្តាប់កាន់តែទ្រាំមិនបាន អ្នកកំលោះពោលសួរវិញ៖

-អូនចេះតែនិយាយសម្តីផ្តេសផ្តាសអញ្ចឹង បើបងកុសលមិនខឹងក៏មិនកើតដែរ! បិសាចអី? ព្រាយអី? អូនដឹងថានេះជាពាក្យប្រមាថកាតទានធ្ងន់ធ្ងរទេ? យើងជាអ្នកមានពូជ ពាក្យអស់នេះមិនមែនសម្រាប់ឲ្យយើងនិយាយទេ!

ភីណាទាល់តម្រិះ នាងមិនដឹងថាហេតុអីក៏គ្មានអ្នកណាព្រមទទួលស្គាល់ការពិតនេះសោះ? នាងខ្ទប់ត្រចៀកពោលខ្លាំងៗដោយក្រេវក្រោធ៖

-ត្រូវហើយ ខ្ញុំនេះខុស ខ្ញុំអាក្រក់ បងឯងចេញទៅ ចេញភ្លាមឥឡូវនេះទៅ ទុកឲ្យខ្ញុំខុស ឲ្យខ្ញុំអាក្រក់ម្នាក់ឯងចុះ ចេញទៅ!

វិទូជ្រួញចិញ្ចើមបន្លឺមកកាន់នាង៖

-ភីណា!

រកតែគេនិយាយមិនបានមួយឃ្លាឲ្យចប់ត្រឹមត្រូវផង នាងក្រមុំស្រែកភ្លាម៖

-នេះជាបន្ទប់ខ្ញុំ បើខ្ញុំមិនពេញចិត្ត គ្មានអ្នកណាមានសិទ្ធិចូលមកទេ! បងចេញទៅវិញទៅបើនៅក៏មិនយល់ចិត្តខ្ញុំដដែល ខ្ញុំនៅម្នាក់ឯងល្អជាង!

ភាគទី១៣

នាងក្រមុំស្ទុះឡើងទៅអង្គុយលើគ្រែយំខ្សឹកខ្សួល នាងអង្គុយទ្រោមក្បាលយំហើយយំទៀតឈឺចិត្ត វិទូដកដង្ហើមធំ អ្នកងាកមើលបរិយាកាសស្ងាត់ច្រៀបជុំវិញទីនេះ អ្នកដឹងថាខ្លួនក៏មិនសមនឹងនៅរវីមរវាមក្នុងបន្ទប់ភីណាយូរតទៅទៀតដែរ ទើបបែរខ្លួនដើរចេញពីបន្ទប់ បន្សល់ឲ្យនាងក្រមុំនៅទ្រហោយំដោយឈឺចិត្តតែម្នាក់ឯង។

មិននឹកស្មានថាពេលខ្លួនហើបមាត់និយាយបកអាក្រាតពីស្រីបិសាចនោះ មិនត្រឹមតែគ្មានអ្នកណាជឿប៉ុណ្ណោះទេ សូម្បីតែបងប្រុសខ្លួន គូដណ្ដឹងខ្លួន ក៏ពួកគេយល់ថាខ្លួនផ្ដេសផ្ដាសដែរ។

នាងជ្រួញចិញ្ចើមដោយមួហ្មង ឯទឹកភ្នែកដែលកើតមកពីកំហឹង និងការឈឺចិត្តក៏នៅតែហូរស្រក់មកមិនឈប់ឈរសោះ តើតទៅគួរប្រឈមមុខនឹងស្រីព្រាយនោះដោយវិធីណា បើហាមាត់និយាយទៅគ្មានអ្នកណាមួយគេព្រមជឿសម្ដីខ្លួនសោះ ឬមួយក៏ត្រូវនៅសម្ងំរង់ចាំទម្រាំវាត្រឡប់មកវិញ រកឱកាសចូលមកសម្លាប់នាងសាជាថ្មីម្ដងទៀត។

អារម្មណ៍ទាំងមូលកំពុងវិលខ្វាល់ជុំវិញបញ្ហាចាក់ស្រេះគួរឲ្យក្ដៅក្រហាយនេះ ក៏ស្រាប់តែឮសំឡេងគោះទ្វារបន្ទប់ តុ តុ! នាងក្រមុំងើបមុខសម្លឹងអ្នកបម្រើវ័យចំណាស់ដែលកំពុងឈរឯមាត់ទ្វារសម្លឹងមកនាងដោយមុខព្រួយបារម្ភ នាងឮគាត់និយាយ៖

-នាងតូច! លោកក្មួយវិទូ អញ្ជើញលោកគ្រូពេទ្យមកដល់ហើយ!

ភីណាជ្រួញចិញ្ចើមមិនចេញស្ដី អ្នកបម្រើចំណាស់ចេញទៅដោយអាការបារម្ភ ភីណាមិនទាន់គិតឃើញយ៉ាងណាផងក៏ស្រាប់តែនៅឯមាត់ទ្វារលេចរូបលោកគ្រូពេទ្យ លើដៃគាត់មានយួរប្រអប់ប្រដាប់ប្រដាពិនិត្យមកជាមួយផង ។គាត់ប្រកបដោយទឹកមុខញញឹម ពោលមកកាន់តរុណី៖

-អ្នកនាង សូមរៀបចំខ្លួនដើម្បីពិនិត្យជំងឺ!

ភីណាងាកមុខមកវិញដោយមិនសប្បាយចិត្ត នាងឧទានដោយអាការសោះកក្រោះ៖

-ខ្ញុំអត់ឈឺអីទេ! ហេតុអ្វីចាំបាច់ពិនិត្យ?

លោកវេជ្ជបណ្ឌិតហាក់ដូចជាភ្ញាក់ផ្អើលជាមួយនឹងអាការនេះ គាត់មិនទាន់ឆ្លើយតបបានថាយ៉ាងណាផង ភីណាពោលបន្តៈ

-អញ្ជើញលោកត្រឡប់ទៅវិញចុះ! នៅហ្នឹងអត់មានអ្នកជំងឺទេ!

លោកវេជ្ជបណ្ឌិតមិនដឹងថាត្រូវនិយាយថាម៉េចតទៅទៀតដែរ ទើបបានជាគាត់គ្រវីក្បាលយឺតៗបែរខ្លួនដើរចុះទៅក្រោមវិញ។ ភីណាជ្រប់មុខដោយមួហ្មង ភ្លាមនោះនាងស្រាប់តែងឿងឆ្ងល់តែម្នាក់ឯង ហេតុអ្វីវិទូបែរជាអញ្ជើញគ្រូពេទ្យឲ្យចូលមកមើលនាងទៅវិញ? ឬមួយក៏គេយល់ថានាងមានបញ្ហាខួរក្បាលទើបបានជាបង្ករឿងទំនាស់ក្នុងផ្ទះ?

គិតឃើញយ៉ាងនេះហើយទើបនាងស្រវាស្ទុះរឹងក្រោកពីគ្រែចុះតម្រង់ទៅជាន់ខាងក្រោមវិញមួយរំពេច។ មកដល់ខាងក្រោមភ្លាម នាងឮសូរមាត់កំលោះគូដណ្ដឹងពោលរអ៊ុះៗនឹងលោកគ្រូពេទ្យនៅឯសាឡុង នាងប្រឹងលាក់ខ្លួនក្បែរថូផ្កាឯមាត់ជណ្ដើរដោយផ្ទៀងត្រចៀកលបស្ដាប់។ ភ្លាមនោះនាងឮសំឡេងអ្នកកំលោះគូស្នេហ៍បន្លឺទៅកាន់លោកគ្រូពេទ្យៈ

-លោកវេជ្ជបណ្ឌិត! កាលពីមុនក្រែងលោកធ្លាប់មានប្រសាសន៍ថារបួសនាងអត់មានប៉ះពាល់ដល់ចំណុចសំខាន់ឯណា ចុះម៉េចក៏ចាប់តាំងពីមានរបួសមកនាងប្រែប្រួលទៅជាធ្វើរឿងខុសប្រក្រតីបន្តបន្ទាប់? ឬមួយថារបួសនៃការប៉ះទង្គិចនោះ មានប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រាសាទទេដឹង? លោកមានមើលរំលងនូវបញ្ហានេះដែរទេ?

ភីណាចងចិញ្ចើមស្ទើរតែដល់គ្នាដោយក្ដីមួហ្មង មិននឹកដល់ថាវិទូមិនត្រឹមមិនយល់ចិត្ត មិនជឿសម្ដីខ្លួនប៉ុណ្ណោះទេ នាងមានបញ្ហាសរសៃប្រាសាទថែមទៀតផង ហាក់ដូចជារកអត់ឱនឲ្យមិនបានសោះ នាងបម្រុងស្រែកកាត់បញ្ចេញកំហឹងទៅកាន់គេទៅហើយក៏ស្រាប់តែឮសូរលោកវេជ្ជបណ្ឌិតបន្លឺមួយៗតបទៅកាន់វិទូ នាងក៏ប្រឹងខំទប់ចិត្តផ្ទៀងត្រចៀកស្ដាប់ប្រសាសន៍របស់គាត់ភ្លាមនោះនាងឮគាត់វាចាៈ

-បើលោកមានគំនិតសង្ស័យយ៉ាងនេះ ខ្ញុំគួរពន្យល់ឲ្យបានច្បាស់លាស់ ថ្វីត្បិតថាមុខរបួសរបស់អ្នកជំងឺបណ្ដាលមកពីការប៉ះទង្គិចពិតមែន ក៏ប៉ុន្តែបើការពិនិត្យរបស់យើងបានធានាអះអាងថាគ្មានប៉ះពាល់ដល់ចំណុចសំខាន់ណាមួយដែលបណ្ដាលឲ្យមានផលអាក្រក់ដល់

ប្រព័ន្ធសរសៃប្រសាទទេនោះ ក៏លោកមិនត្រូវមានទុទ្ធិដ្ឋិនិយមសង្ស័យទៅផ្លូវអាក្រក់នោះដែរ ប៉ុន្តែផ្ទុយទៅវិញប្រសិនជាព្រោះតែករណីណាមួយផ្សេងដែលអ្នកជំងឺបានជួបប្រទះហើយអាចប៉ះទង្គិចដល់ប្រព័ន្ធសរសៃប្រាសាទរបស់នាង ក៏ខ្ញុំមិនហ៊ានសន្និដ្ឋានដែរ ប៉ុន្តែក៏លុះណាតែពិនិត្យបានត្រឹមត្រូវទើបខ្ញុំហ៊ានអះអាង! ពីព្រោះថានេះគឺជារឿងធ្ងន់ធ្ងរប៉ះពាល់ដល់សតិអារម្មណ៍របស់មនុស្ស យើងមិនអាចធ្វើការសន្និដ្ឋានតែផ្ដាសកើតនោះទេ!

វិទូងក់ក្បាលផ្ងក់ៗ ទំនងជាអ្នកកំពុងរិះគិតពីប្រសាសន៍របស់លោកវេជ្ជបណ្ឌិតដែលមានហេតុផលទំនងសមស្រប ខណៈនោះអ្នកពោលទៅកាន់គាត់៖

-ណ្ហើយ អីចេះចុះ ពេលនាងអាចឃុំគ្រងខ្លួនឯងបានប្រសើរជាងមុន សឹមខ្ញុំអញ្ជើញលោកម្ដងទៀត ដល់ពេលដែលលោកបានពិនិត្យត្រឹមត្រូវហើយ មុខជាអាចសន្និដ្ឋានបានច្បាស់លាស់ហើយ!

លោកវេជ្ជបណ្ឌិតក្រោកពីសាឡុង ទាំងវាចាតបនឹងអ្នកកំលោះវិញ៖

-បាទ! ខ្ញុំលាទៅវិញសិនហើយ!

វិទូក្រោកពីសាឡុងដើម្បីជាកិច្ចជូនដំណើរ ភ្លាមនោះអ្នកអួនដើរចេញមកជូនដំណើរលោកវេជ្ជបណ្ឌិតចេញទៅក្រៅដែរ ទុកឲ្យវិទូនៅឈររិះគិតតែម្នាក់ឯង។ កណ្ដាលបរិយាកាសស្ងាត់ច្រៀបរបស់គេហដ្ឋានធំល្វឹង ឮតែស្នូរស្បែកជើងលាន់កុបៗទង្គិចនឹងកម្រាលឥដ្ឋ វិទូងើបមុខសម្លឹងនាងក្រមុំភីណាដែលប្រកបដោយទឹកមុខស្មើធេងដើរយឺតៗចុះមកពីលើជណ្ដើរ គេមិនដឹងថានាងបានឮសម្ដីដែលខ្លួនពិគ្រោះជាមួយវេជ្ជបណ្ឌិតឬក៏អត់ ប៉ុន្តែគ្រាន់តែឃើញទឹកមុខក៏ដឹងច្បាស់ថា នាងមិនសប្បាយចិត្តដែរ អ្នកហើបមាត់ពោលទៅកាន់នាង៖

-ភីណា?

មិនរង់ចាំឲ្យវិទូនិយាយចប់បានមួយឃ្លាឡើយ នាងក្រមុំពោលកាត់ដោយសូរសព្ទអាក់រអួល ៖

-កុំមកហៅខ្ញុំ!

វិទូបញ្ចេញសភាពងឿងឆ្ងល់លើផ្ទៃមុខ អ្នកពោលមកកាន់នាង៖

-អូនទប់ចិត្តឲ្យល្អបន្តិច បានដែរអត់ភីណា?

ភីណាបង្ហាញអាការហួសចិត្ត នាងសើចខឹកក្នុងបំពង់ក ដោយក្រពាត់ដៃបន្លឹតបទាំងទឹកមុខស្មើ ប៉ុន្តែសូរសព្ទនៅតែរអាក់រអួលដដែល៖

-បងសង្ស័យលើស្មារតីចងចាំរបស់ខ្ញុំ បងសង្ស័យថាសរសៃប្រសាទខ្ញុំមានបញ្ហា បងគិតថាខ្ញុំនេះឆ្កួត ប៉ុន្តែខ្ញុំសូមជម្រាបបងឲ្យច្បាស់ទៅចុះ ស្មារតីខ្ញុំនៅល្អណាស់ ខ្ញុំគ្មានឆ្កួតទេ ខ្ញុំគ្មានខុសទេ! ហើយក៏មិនបាច់ទប់ចិត្តអីទាំងអស់!

វិទូបង្ហាញក្តីតប់ប្រមល់លើផ្ទៃមុខ អ្នកឧទានតបទៅកាន់នាង៖

-ប៉ុន្តែគឺយើងមានការយល់ខុស មិនចេះថ្លឹងថ្លែងមុននិយាយមុនស្តីបណ្តាលឲ្យក្នុងផ្ទះមានរឿងធំអញ្ចឹង! ចេញពីពេទ្យមកភ្លាម ក៏មកដល់ផ្ទះបង្ករឿងផ្តេសផ្តាសចំពោះអ្នកបង ថ្ងៃនេះហើយក៏នៅមិនព្រមបញ្ឈប់ទៀត យល់ថាខ្លួនឯងត្រូវទៀត?

ភីណាបញ្ចេញទឹកមុខតប់ប្រមល់សម្លឹងថ្មេមករកអ្នកកំលោះ នាងឧទានទាំងអួលណែនក្នុងបំពង់ក៖

-វិទូ អ្នកណាគេមិនយល់ចិត្តខ្ញុំ ក៏ខ្ញុំមិនរវល់ប៉ុន្មានដែរ ប៉ុន្តែ បង! បងជាមនុស្សជិតស្និទ្ធរបស់ខ្ញុំបែរជាបងមិនយល់ចិត្តខ្ញុំសោះ បងពូកែតែខាងបន្ទោស បងមានសួរខ្ញុំអត់? បងមានសួរថាហេតុអ្វីបានជាខ្ញុំមកដល់ផ្ទះវិញភ្លាមមានអាការមួហ្មងចំពោះបងថ្លៃខ្ញុំទេ?

វិទូដឹងថាខ្លួនក៏ជ្រុលហួសហេតុបន្តិចដែរក្នុងរឿងនេះ ក្នុងពេលដែលនាងនៅមិនទាន់ប្រមូលអារម្មណ៍បានត្រឹមត្រូវយ៉ាងនេះ គួរណាស់តែខ្លួនពន្យល់លួងលោមនាងតាមសម្រួល មិនគួរណាហាមាត់បន្ទោសនាងយ៉ាងនោះទេ ព្រោះតែគិតឃើញយ៉ាងនេះហើយ ទើបអ្នកកំលោះងើបមុខសម្រួលអាការឲ្យល្អជាងមុន បន្លឺវាចាទៅកាន់នាង៖

-ឥឡូវនេះអូនមានហេតុផលអីខ្លះ អូនឆាប់និយាយទៅ!

ភីណាងាកមុខចេញ នាងពោលយ៉ាងតោះតើយ៖

-ឥឡូវនេះបងចាត់ទុកថាខ្ញុំជាមនុស្សវង្វេងស្មារតីទៅហើយ ខ្ញុំនិយាយ ឬមិននិយាយ វាដូចតែគ្នាហ្នឹង!

នាងបន្លឺខ្លាំងៗទៅកាន់អ្នកបម្រើចំណាស់ដែលកំពុងដើរយឺតៗចូលមកពីខាងក្រៅ៖

-មីងអួន! មីងឡើងទៅរៀបអីវ៉ាន់ជាមួយខ្ញុំ!

វិទូសម្លឹងដំណើរនាងដែលដើរយ៉ាងរហ័សសំដៅទៅជាន់ខាងលើ ដោយមានទាំងអ្នកបម្រើចំណាស់ឡើងទៅតាមពីក្រោយផង។ អ្នកកំលោះដកដង្ហើមធំដោយតានតឹងក្នុងចិត្ត អ្នកនឹកមិនយល់ថា ម៉េចនៅសុខៗ ភីណាត្រូវរបួសចូលមន្ទីរពេទ្យ ហើយពេលត្រឡប់មកផ្ទះវិញ បង្កឲ្យមានរឿងម្តងហើយម្តងទៀតយ៉ាងដូច្នេះ? ណាមួយនាងថែមទាំងមានចរិតមានះឆេវឆាវប្លែកជាងពេលមុនទៀតផង។ បើនាងនិយាយគ្មានហេតុគ្មានផលយ៉ាងនេះ តើឲ្យអ្នកដោះស្រាយរឿងស្មុគស្មាញទាំងអស់នេះដោយវិធីណា?

អ្នកកំលោះនឹកដល់កាយវិការរបស់ភីណា អម្បាញ់មិញនៅឯបន្ទប់ខាងលើ ពេលដែលនាងស្ទុះស្ទាទៅចាក់បងថ្លៃស្រីរបស់ខ្លួនឲ្យមានរបួសមុតយ៉ាងជ្រៅហូរឈាមជោកជាំលើកម្រាលឥដ្ឋ អ្នកមិនយល់សោះថាម៉េចក៏ភីណាដាច់ចិត្តប្រព្រឹត្តកាយវិការរបៀបនោះ? តាំងពីពេលមុនមក អ្នកក្នុងផ្ទះទាំងអស់អ្នកណាក៏ដឹងដែរថា ភីណា និងបងថ្លៃមានមនោសញ្ចេតនាល្អនឹងគ្នាណាស់ ក៏ព្រោះតែភីណាជាក្មេងកំព្រាគ្មានឪពុកម្តាយតាំងពីតូច ឯអ្នកស្រីកុលាបដែលជាបងថ្លៃក៏ជាស្ត្រីមានសារជាតិស្លូតបូត ស្រលាញ់ថ្នាក់ថ្នមភីណាដោយស្មោះស្ម័គ្រដែរ ប៉ុន្តែចាប់តាំងពីនាងក្រមុំភីណាត្រូវរងគ្រោះថ្នាក់ចរាចរណ៍ចូលសម្រាកពេទ្យកាលណា ពេលនាងមកដល់ផ្ទះវិញ រវាងនាង និងបងថ្លៃក៏ស្រាប់តែលេចចេញនូវបញ្ហាជាច្រើនខុសពីប្រក្រតី ភាពស្និទ្ធស្នាលរវាងបងប្អូនគេទាំងពីរហាក់បីដូចជាត្រូវរលត់បាត់អស់នៅហើយ ហេតុការណ៍ទាំងនេះហើយដែលបណ្តាលឲ្យវិទូរកគិតមិនយល់សោះ។

អារម្មណ៍មិនទាន់ដកជ្រះស្រឡះចេញពីការរិះគិតនៅឡើយ ក៏ស្រាប់តែឮសូរស្នូរជើងចុះមកពីជាន់ខាងលើសាជាថ្មី រួមជាមួយប្រយោគលាយឡំដោយអាការព្រួយបារម្ភរបស់អ្នកបម្រើចំណាស់៖

-នាងតូច! កុំធ្វើអញ្ចឹងអី! កុំទៅអីនាងតូច!

វិទូងើបមុខសម្លឹងទៅស្រីស្រស់គូស្នេហ៍ដែលកំពុងយួរវ៉ាលីស៍យ៉ាងធំដើរញាប់ជើងស្ទេរចុះមកខាងក្រោម នាងស្រែកហៅរកសូហ្វ័រឡាន៖

-ពូស្លួស! ពូស្លួស! ពូស្លួសនៅឯណា!

វិទូចងចិញ្ចើមដើរចូលទៅក្បែរនាងទាំងពោលសួរដោយក្ដីងឿងឆ្ងល់៖

-គិតធ្វើអីហ្នឹងភីណា? អូនគិតយកអីវ៉ាន់ទៅណា?

នាងក្រមុំអូសវ៉ាលីស៍ចុះមកបណ្ដើរ មាត់នៅតែស្រែករកស្លូហ្ស៍ដោយមិនរវល់យកត្រចៀកស្ដាប់សម្ដីកំលោះគូដណ្ដឹងសោះ៖

-ពូស្លួស! នៅឯណាហើយ ពូស្លួស?

អ្នកបម្រើចំណាស់បង្ហាញក្ដីបារម្ភលើផ្ទៃមុខ គាត់ពោលប្រាប់ទៅនាង៖

-នាងតូច ពូស្លួសជូនលោកប្រុសទៅក្រៅអម្បាញ់មិញហើយ នាងតូចទុកអីវ៉ាន់ទៅ កុំទៅណាអី!

ភីណាបញ្ចេញអាការមួហ្មងខ្លាំងក្លាជាងមុន នាងយួរវ៉ាលីស៍ដើរញាប់ស្មេរតម្រង់កាន់ទ្វារ ទាំងមាត់ពោល៖

-គ្មានគាត់ក៏ខ្ញុំទៅបានដែរ មីងមិនបាច់ឃាត់ឃាំងខ្ញុំទេ!

នាងដើរញាប់ជើងស្មេរដោយមិនងាកក្រោយ អ្នកបម្រើវ័យចំណាស់នៅតែស្ទុះទៅតាមអង្វរឃាត់នាង៖

-នាងតូច! កុំទៅអី លោកប្រុសត្រឡប់មកវិញ គាត់បន្ទោសខ្ញុំស្លាប់ហើយ! កុំទៅអីណ៎ា!

ភីណាទុចដំណើរនាងបែរក្រោយសម្លឹងមកកាន់អ្នកបម្រើជំនិត នាងពោលប្រាប់ទៅគាត់វិញដោយរលីងរលោងទឹកភ្នែក៖

-មីងកុំបារម្ភ! បងខ្ញុំគាត់មិនបន្ទោសមីងទេ គាត់ការពារស្រីព្រាយនោះលែងចេះគិតប្អូនហើយ បានខ្ញុំទៅគាត់មុខតែបាននៅសុខស្រួល! មីងឃាត់ខ្ញុំ ប្រយ័ត្នខ្ញុំខឹងទាំងមីងទៀត!

មីងចំណាស់ថយក្រោយពីនាងក្រមុំដោយក្ដីបារម្ភ វិទូវិញមួហ្មងណាស់ដែលកាលបើមើលឃើញថាភីណារឹងរូសយ៉ាងនេះ អ្នកកំលោះចូលទៅក្បែរនាងឈររាំងពីមុខនាងដោយអាការដូចជាហួសចិត្ត៖

-គិតទៅណា? ធ្វើតាមអំពើចិត្តអញ្ចឹងទៅកើតដែរអ្ហស់?

ភីណាតបដោយមិនមើលមុខគេ៖

-ខ្ញុំទៅណាមិនបាច់សុំការអនុញ្ញាតពីបងទេ! ផ្ទះនេះខ្ញុំស្អប់ ខ្ញុំនៅមិនកើត ខ្ញុំទៅនៅម្នាក់ឯងវិញ វាគ្រាន់បើជាង បើខ្ញុំនៅទីនេះតទៅទៀត ទោះជាមិនឆ្កួតក៏គង់តែក្លាយទៅជាឆ្កួតមែនមិនខាន!

វិទូមិនរវល់និយាយជាមួយនាងទេ អ្នកលូកដៃទៅបម្រុងទាញយកវ៉ាលីស៍ចេញ នាងពោលមកកាន់អ្នកទាំងអាការមិនពេញចិត្ត៖

-បងកុំរារាំងខ្ញុំ បងធ្វើឲ្យខ្ញុំខឹងគ្រប់គ្រាន់ហើយ!

សំឡេងអ្នកបម្រើចំណាស់នៅតែអង្វរមកពីក្រោយខ្នង៖

-នាងតូច កុំទៅអី! កុំទៅអីនាងតូច!

នាងក្រមុំមិនរវល់ស្តាប់ នាងគិតតែពីយួរវ៉ាលីស៍ដើរញាប់ជើងស្មេរតម្រង់ទៅកាន់មាត់ទ្វារ វិទូពោលសួរពីក្រោយខ្នង៖

-បងនិយាយហើយ អូននៅមិនស្តាប់ទៀតអ្ហស់?

ភីណាទុចដំណើរ នាងមិនងាកក្រោយទេ ប៉ុន្តែនាងហើបមាត់តបដោយសូរសព្ទខឹងណែន៖

-ខ្ញុំមិនស្តាប់ទេ ខ្ញុំមិនស្តាប់អ្នកណាទាំងអស់ ព្រោះអីពេលខ្ញុំនិយាយក៏គ្មានអ្នកណាព្រមស្តាប់ខ្ញុំដែរ!

សំឡេងទូរសព្ទរោទ៍ញាប់រន្ថើន វិទូឈ្វោកដកទូរសព្ទពីចង្កេះមកស្តាប់ ឆ្លៀតពេលនោះដែរភីណាឈានជើងចេញទៅយ៉ាងរហ័ស រកតែវិទូពោលឃាត់ក៏មិនទាន់។

វិទូស្តាប់ទូរសព្ទបណ្តើរ ចិត្តមួយបារម្ភភីណាបណ្តើរ ប៉ុន្តែដឹងថាសំឡេងដែលវាយទូរសព្ទមកនោះប្រាប់មកថាយ៉ាងណាខ្លះទេ បានជាពេលនោះអ្នកកំលោះស្រាប់តែងាកមករកភីណាដែរ ប៉ុន្តែនាងចេញទៅបាត់ទៅហើយ។

វិទូស្ទុះចេញទៅក្រៅយ៉ាងរហ័ស ដោយមាត់ស្រែកហៅ៖

-ភីណា! ភីណា!

ប៉ុន្តែសួនច្បារខាងមុខផ្ទះគ្មានឃើញស្រមោលនាងសោះ ឃើញតែអ្នកបម្រើចំណាស់ដើរចូលមកវិញដោយទឹកមុខស្រពោន អ្នកកំលោះប្រញាប់ប្រញាល់ពោលសួរទៅកាន់គាត់ភ្លាម៖

-មីង! ឯណាភីណា?

អ្នកបម្រើរូបនោះតបដោយក្ដីបារម្ភពោលក្នុងចិត្ត៖

-ខ្ញុំឃាត់មិនស្ដាប់ទេ! នាងតូចជិះរ៉ឺម៉កកង់បីទៅហើយ យកទាំងសោ Apartment នៅបឹងកេងកងទៅផង!

សេចក្ដីខ្វល់ខ្វាយលេចចេញតាមរយៈពន្លឺនៃកែវភ្នែករបស់អ្នកកំលោះរូបនេះ ទោះបីថាគេមិននិយាយចេញមកក៏អ្នកបម្រើចំណាស់មើលដឹងថាគេកំពុងពិបាកចិត្តយ៉ាងខ្លាំងព្រោះតែរឿងទាំងអស់របស់ភីណាដែរ។

វិទូលើកទូរសព្ទមកផ្អឹបនឹងត្រចៀកសាជាថ្មី ដោយបន្លឺទាំងក្រៀមក្រំទៅកាន់លោកកុសលនៅចុងម្ខាង៖

-ភីណាចេញពីផ្ទះហើយ! តែបងកុំបារម្ភ ចាំខ្ញុំទៅតាមមើលគេ! ឲ្យគេបាត់ខឹងបន្តិចសិនទៅចាំលួងគេទៅជួបពេទ្យ!

អ្នកកំលោះឈានទៅរកជំនិះដែលចតចោលក្បែរសួនច្បារ។ នាយទៅដល់កាលណាចាប់ស្រវាប្រុងបើកមករកនារីគូស្នេហ៍នៅបឹងកេងកងគាប់ជួនជាមីងអួនរត់មករលះរលាំងសាជាថ្មីថា៖

-លោកក្មួយ! នេះថ្នាំរបស់នាងតូចភីណា! នាងតូចភ្លេចយកទៅហើយ! មិនគួរខានលេបទេព្រោះជំងឺនៅធ្វើទុក្ខ!

វិទូលូកដៃទទួលប្រអប់ថ្នាំទាំងងក់ក្បាល់ៗផ្ងក់ៗ៖

-ចាំខ្ញុំយកទៅឲ្យគេ! មីងកុំបាច់ព្រួយទេ! ចាំគេលែងខឹងខ្ញុំនាំគេមកវិញ!

នាយប៉ូលិសបញ្ឆេះម៉ូតូធំចាកចេញពីគេហដ្ឋានក្រោមពន្លឺភ្នែកព្រួយបារម្ភរបស់ស្ត្រីចំណាស់។

------------------ភាគទី១៤

វគ្គទី៦

អាថ៌កំបាំង

ស្នូរចាបយំខ្សៀវខ្វារខាងក្រៅបង្អួច ភីណាអង្គុយលើគ្រែសម្លឹងទៅខាងក្រៅផ្ទះដោយទឹកមុខស្ងួត។

ជាការពិតណាស់ ទីនេះមិនមែនជាផ្ទះរបស់ខ្លួន តើរស់នៅដោយសប្បាយចិត្តយ៉ាងម៉េចកើតទៅ? នាងសម្លឹងទៅមីងម៉ាប់ដែលខំរត់ឡើងរ៉ឺម៉កមកតាមបម្រើនាង។គាត់កំពុងរៀបសម្លៀកបំពាក់ចូលទៅក្នុងទូ នាងពោលសួរដោយសូរសព្ទស្រាលៗ៖

-មីង! រៀបប៉ុណ្ណឹងបានហើយ មីងទៅផ្ទះធំវិញទៅក្រែងអ្នកស្រីធំរបស់មីងត្រូវការរក! ឥវ៉ាន់ទាំងនេះទុកខ្ញុំរៀបខ្លួនឯងចុះ!

-ពុទ្ធោអ្នកនាងតូចរបស់មីង! ឲ្យមីងទៅចោលអ្នកនាងម៉េចកើត! បានអ្នកណាថែទាំបាយម្ហូបអីនោះ? នៅផ្ទះធំ មានអ្នកអួនហើយ! អ្នកនាងឃ្លានទេ ចាំមីងទៅរកទិញម្ហូបសិន!

នារីតូចច្រឡឹងហូរទឹកភ្នែកអាណិតខ្លួន នាងនិយាយផងជូតជលនេត្រផង៖

-ខ្ញុំអត់ឃ្លានអីទាំងអស់មីង! ខ្ញុំចង់នៅស្ងាត់!

អ្នកបម្រើរូបនោះងាកមកសម្លឹងមាណវី ប្រហែលជាយល់ថាភីណាមិនចង់ឲ្យអ្នកណានៅរំខានអញ្ចឹងហើយទើបម្នីម្នាក្រោកចេញទៅទាំងឆ្លៀតបន្លឺប្រាប់៖

-បើអញ្ចឹងពេលនាងតូចណ៎ា ត្រូវការអ្វីស្រែកហៅខ្ញុំចុះ!

ភីណាឆ្លើយតបទាំងច្រត់ដៃក្រោកពីគ្រែ៖

-ដឹងហើយ!

អ្នកបម្រើរូបនោះចាកចេញពីបន្ទប់ទៅ ភីណាដើរមកអង្គុយបត់ជើងរៀបសម្ភារៈប្រើប្រាស់របស់ខ្លួនទាំងអស់ដាក់លើទូសំអាងទាំងទឹកមុខក្រៀមក្រំ នាងនឹកដល់បងប្រុសខ្លួន គាត់គឺជាបងប្រុសតែមួយគត់ ហើយក៏ជាអ្នកដែលនាងរំពឹងតែមួយគត់បន្ទាប់ពីឪពុកម្ដាយចែកឋានទៅ

ឥឡូវនេះគាត់រវល់តែលុះក្រោមល្បិចកលរបស់ស្រីបិសាច សូម្បីតែប្អូនស្រីរបស់ខ្លួន ក៏លែងគិតដល់ហើយដែរ មិនដឹងទ្រាំដល់ពេលណាទើបគាត់អាចភ្ញាក់ខ្លួននឹងរឿងពិត មុខមាត់ពិតរបស់ប្រពន្ធគាត់នោះទេ ឥឡូវនេះនាងចាកចេញពីផ្ទះព្រោះតែមិនអាចទ្រាំបានចំពោះមុខហេតុការណ៍ដ៏តឹងតែងដែលស្រីបិសាចនោះជាអ្នករៀបចំឡើង នាងយល់ថាតាមមើលគឺបងប្រុសខ្លួនរវល់តែឈឺឆ្អាលនឹងភរិយារបស់គាត់ សូម្បីតែប្អូនស្រីខ្លួនចេញទៅនៅក្រៅផ្ទះក៏គាត់មិនរវល់ដែលមើលទៅ!

នាងស្រាប់តែចាប់អារម្មណ៍ថា តូចចិត្តចំពោះវាសនាខ្លួនណាស់ កើតមកគ្មានឪពុកម្ដាយរស់នៅជិតកាយថ្នមថែរក្សាដូចគេដទៃ មានតែបងប្រុសម្នាក់ ឥឡូវនេះគាត់ក៏លែងយកចិត្តទុកដាក់នឹងនាងទៀត  ទោះកើតទុក្ខសោកសៅក៏មានតែអង្គុយក្ដុកក្ដួលម្នាក់ឯងប៉ុណ្ណោះ រកអ្នកឈឺឆ្អាលម្នាក់នៅក្បែរខ្លួនគ្រាន់នឹងរំលែកទុក្ខក៏មិនបានដែរ។ កាន់តែគិតចិត្តរឹងរឹតតែសោកសៅទ្វេឡើង តំណក់ទឹកភ្នែកដែលកើតចេញពីភាពឯកា និងការអាណិតខ្លួនប្រជែងគ្នាហូរសស្រាក់កាត់ផែនថ្ពាល់ដែលស្រស់ផូរផង់ ល្មមគ្នានោះដែរសូរសព្ទស្រាលៗមួយលាន់ឮមកពីខាងក្រោយខ្នង៖

-បើមិនសប្បាយចិត្តដដែល ចេញពីផ្ទះមកធ្វើអី?

ភីណាភ្ញាក់ដូចគេកន្ត្រាក់  តាមរយៈផ្ទាំងកញ្ចក់ នាងអាចមើលឃើញរូបអ្នកកំលោះវិទូដែលកំពុងឈរខ្ពស់សង្ហាពីក្រោយខ្នង។ នាងក៏ប្រញាប់ប្រញាល់លើកដៃជូតទឹកភ្នែក និងឈ្ងោកមុខដោយអាការស្រពាប់ស្រពោន៖

-អ្នកណាឲ្យបងចូលបន្ទប់ខ្ញុំ?

វិទូដើរចូលមកកាន់តែជិត ប៉ុន្តែភ្នែកទាំងគូនៅតែមិនដកពីរូបក្រមុំគួរស្នេហ៍នៅឡើយទេ អ្នកពោលសួរស្រាលៗមកកាន់នាង៖

-នៅខឹងទៀត?

ភីណាឈ្ងោកមុខរៀបសម្ភារៈប្រើប្រាស់បន្តដោយមិនឆ្លើយតបនឹងអ្នកកំលោះសោះ វិទូដាក់បង្អុយចុះជិតនាងទាំងឈ្ងោកមើលមុខនាងផងនិយាយផង៖

-គិតនៅហ្នឹងដល់អង្កាល់? បានយករបស់មកច្រើនម្ល៉េះ?!

នាងក្រមុំចងចិញ្ចើមតែមិនខ្ចីឆ្លើយតបសម្ដីបុរសគូស្នេហ៍។ ភ្លាមនោះនាងឮគេវាចាលួងចិត្ត ស្រាលៗក្បែរត្រចៀក៖

-និយាយមក! និយាយរឿងរ៉ាវតាំងពីដើមដល់ចប់ណា៎! បងនៅចាំស្ដាប់! បងអត់ទៅណាទេ!

ភីណាដៀងភ្នែករិះគិត នាងងើបមុខសម្លឹងបុរសទាំងទឹកភ្នែកព្រិចៗ ប៉ុន្តែតាមពិតគឺនាងកំពុងមានចិត្តត្រេកអរ។ យ៉ាងណាក៏នាងយល់ថានាងពិតជាកំពុងត្រូវការគេបំផុតក្នុងកាលៈទេសៈនេះ។ វាចាចុងក្រោយរបស់គេធ្វើឲ្យនាងនឹកឃើញដល់រឿងអកុសលដែលកើតឡើងលើរូបស្រីជាបងថ្លៃរបស់ខ្លួននារាត្រីដែលមានភ្លៀងធ្លាក់មិនឈប់ឈរនោះសាជាថ្មី។

កាលយប់នោះ គាត់បានដាច់ខ្យល់ស្លាប់បាត់ទៅហើយ ក៏ស្រាប់តែក្រោយមកបែរជាមានជីវិតរស់ឡើងវិញ ណាមួយថែមទាំងមានលក្ខណៈខុសពីមនុស្សធម្មតា។ នាងបានឃើញគាត់បរិភោគសាច់ឆៅផ្ទាល់នឹងភ្នែក  បន្ទាប់មកក៏ឡើងមកប្រុងប្របាច់កនាងក្នុងបន្ទប់រហូតដល់មានរឿងធំផ្ទុះឡើងទាំងព្រហាម។

វិទូសម្លឹងមុខនារីម្ចាស់ចិត្ត អ្នកកំលោះឃើញនាងបង្ហាញភាពស្លេកស្លាំងសើចលើផ្ទៃមុខ អ្នកក៏កើតក្ដីងឿងឆ្ងល់លាយឡំនឹងភាពឈឺឆ្អាល គេលើកដៃអង្អែលស្មានាងស្រាលទាំងសងខាងល្មមពេលភីណាពោលទៅកាន់គេដោយទឹកមុខស្លេកស្លាំង៖

-វិទូ! អ្នកបងគួរឲ្យសង្ស័យណាស់ គាត់គួរឲ្យខ្លាចណាស់ បងដឹងទេគាត់ក៏បានដាច់ខ្យល់ស្លាប់ម្ដងហើយ ក្រោយមកបែរជារស់ឡើងវិញ !

អ្នកកំលោះវិទូសម្លឹងមកស្រស់ស្រីដោយក្រសែភ្នែកពេញប្រៀបទៅដោយក្ដីសង្ស័យ តាមពិតគឺអ្នកកំលោះមិនយល់សម្ដីនាងដែលបាននិយាយនេះឡើយ ប៉ុន្តែឃើញទឹកមុខនាងជាក់ស្ដែងពេកអ្នកក៏ទៅជានៅស្ងៀមរង់ចាំឲ្យនាងនិយាយទៀត។ ភីណាផ្ដោតភ្នែកសម្លឹងអ្នកកំលោះ កាលបើឃើញគេមានអាកប្បកិរិយាហាក់រង់ចាំស្ដាប់បែបនេះ នាងបែរជាចងចិញ្ចើមពោលសួរវិញដោយមិនអស់ចិត្ត៖

-បងជឿសម្ដីខ្ញុំអត់ហ្នឹង?

វិទូប្រមូលអារម្មណ៍ដែលកំពុងបែកខ្ញែកដោយក្ដីច្របូកច្របល់នោះមកវិញ គេញាក់ស្មាតបមកកាន់មាណវី៖

-បងនៅមិនទាន់យល់នៅឡើយ! អូននិយាយឲ្យច្បាស់មក!

ភីណាឈ្ងោកមុខដោយចិត្តច្របូកច្របល់ អារម្មណ៍ខ្វាយខ្វល់កំពុងរុកគួនចិត្តខ្លាំងក្លាណាស់ នាងយល់ថាបើលាក់ទុកក្នុងទ្រូងទៀតក៏មានតែធ្វើឲ្យមិនអស់ចិត្តនៅមិនសុខតែប៉ុណ្ណោះ ដូច្នោះហើយទើបនាងសម្រេចចិត្តដោយងើបមុខបន្លឺប្រាប់ទៅកាន់នាយសាជាថ្មី៖

-មិនមែនអូនមិនចង់និយាយទេ ប៉ុន្តែគឺគ្មានអ្នកណាទុកឱកាសឲ្យអូននិយាយសោះ គឺយប់ដែលក្នុងផ្ទះគ្មានអ្នកណានៅនោះ ក្នុងផ្ទះធំមានតែអ្នកបងហើយ និងខ្ញុំ។ យប់នោះនឹកទៅគួរឲ្យខ្លាចណាស់ ភ្លៀងធ្លាក់យ៉ាងខ្លាំងតាំងតែពីព្រលប់រហូតដល់យប់ជ្រៅក៏នៅមិនទាន់រាំងទៀត។ ខ្ញុំ និងអ្នកបងសុទ្ធតែគេងមិនលក់ដូចគ្នាក៏នាំគ្នាអង្គុយនៅសាឡុងឯបន្ទប់ទទួលភ្ញៀវ។ ឯយប់ក៏កាន់តែជ្រៅ ពេលនោះស្រាប់តែឮនៅជាន់ខាងលើមានស្នូរជើងមនុស្សរត់ ឆ្ងល់ថាកណ្តាលយប់អញ្ចឹងតើមានអ្នកណាចូលមករត់ក្នុងផ្ទះយើងបែបនេះ ទាំងខ្ញុំ ទាំងអ្នកបងសុទ្ធសឹងភ័យតែ អ្នកបងនាំខ្ញុំឡើងទៅជាន់ខាងលើរកមើលទៅមើល៍ថាតើមានមនុស្សលួចចូលមកឬក៏អត់ ពេលឡើងទៅដល់ យើងទាំងពីរបានឮសំឡេងមនុស្សនិយាយគ្នារអ៊ុះៗមែនឯក្នុងបន្ទប់ដាក់វត្ថុបុរាណឯណោះ។

ភីណាបង្អង់បន្តិច ទើបពោលបន្តប្រាប់ទៅអ្នកកំលោះគូស្នេហ៍៖

-កាលណោះខ្ញុំ និងអ្នកបងសុទ្ធតែភិតភ័យណាស់ ខ្ញុំនៅចាំថាមុននឹងឈានចូលទៅក្នុងបន្ទប់វត្ថុបុរាណអ្នកបងបានកាន់ថូដែលតាំងមុខបន្ទប់ទៅជាមួយផង ប៉ុន្តែពេលដែលយើងបើកទ្វារចូលទៅដល់ ក៏ស្រាប់តែឃើញមានមនុស្សប្រុសប្លែកមុខពីនាក់ កំពុងឈរនៅរានហាលនៃបន្ទប់វត្ថុបុរាណនោះ លើដៃពួកគេមានកាន់ពូថៅមួយម្នាក់ផង កាលយប់នោះអ្នកបងភិតភ័យរហូតដល់របូតដៃធ្វើជ្រុះថូដែលគាត់កាន់នោះខ្ទាយទៅលើឥដ្ឋ រួចបន្ទាប់មកពួកយើងគិតថាមនុស្សកាន់ពូថៅពីរនាក់នោះប្រាកដជាចោរហើយ ពេលដែលបែរក្រោយទៅរកអ្នកបងស្រាប់តែឃើញគាត់កំពុងដួលត្រឡប់ត្រឡិនចុះមកជាន់ខាងលើ ខ្ញុំឃើញផ្ទាល់នឹងភ្នែក អ្នកបងដួលធ្លាក់ចុះមកដល់ជាន់ខាងក្រោម រួចក៏ត្រូវបោកទៅនឹងជើងសាឡុងយ៉ាងខ្លាំងទៀត ខ្ញុំឃើញគាត់ដេកស្ងៀមនៅទីនោះ លែងកម្រើកទៅហើយ ខ្ញុំចូលទៅជិតគាត់អង្រួនគាត់យ៉ាងណាក៏គាត់មិនដឹងខ្លួនវិញដែរ បន្ទាប់មកខ្ញុំដឹងថាលែងមានដង្ហើម គាត់ស្លាប់បាត់ទៅហើយ! គាត់ស្លាប់មែន!

និយាយដល់ត្រង់ណេះ ភីណាខ្ទប់មុខទ្រហោយំ នាងពោលបន្តទាំងអណ្ដឹតអណ្ដក៖

-ខ្ញុំទូរសព្ទទៅរកបង ប៉ុន្តែទូរសព្ទក៏ដាច់ទៀត ខ្ញុំស្លន់ស្លោណាស់ ខ្ញុំនឹកមិនឃើញថាត្រូវធ្វើយ៉ាងម៉េចសោះ ខ្ញុំក៏បើកឡានចេញពីផ្ទះទៅរកបង ប៉ុន្តែយប់នោះភ្លៀងខ្លាំងពេក ចិត្តខ្ញុំក៏កំពុងវង្វេងវង្វាន់ទៀត ខ្ញុំក៏ជួបគ្រោះថ្នាក់ចរាចរណ៍តែម្ដងទៅ។

វិទូសម្លឹងទៅកាន់តរុណីដោយក្រសែភ្នែកមុតថ្លា ក្នុងចិត្តអ្នកកំលោះគិតឃើញយ៉ាងណាក៏គ្មានអ្នកណាអាចដឹងបាននៅឡើយ ប៉ុន្តែគេនៅមិនទាន់ហើបមាត់និយាយថាយ៉ាងម៉េចទាល់តែសោះ ភ្លាមនោះភីណាពោលបន្តដោយសូរសព្ទរអាក់រអួល៖

-ពេលខ្ញុំចេញពីពេទ្យមកវិញ ខ្ញុំឆ្ងល់ណាស់ត្បិតអីព្ទបងបន្ទោសថាខ្ញុំចេញពីផ្ទះទាំងយប់ទើបជួបគ្រោះថ្នាក់ចរាចរណ៍! ណាមួយពេលត្រឡប់មកដល់ផ្ទះវិញបែរជាឃើញអ្នកបងនៅរស់ជ្រងោទៅវិញ បងនិយាយទៅមើលថាតើពេលនោះខ្ញុំមានអារម្មណ៍យ៉ាងណា ខ្ញុំស្រងាកចិត្តខ្លាំងណាស់ ព្រោះតែមីងអួនប្រាប់ខ្ញុំថា មានទូរសព្ទប្រាប់ពីមន្ទីរពេទ្យមក ទើបគាត់ដឹងថាខ្ញុំមានរបួស ប៉ុន្តែខ្ញុំនៅចាំច្បាស់ណាស់ថា កាលយប់នោះពេលខ្ញុំទូរសព្ទទៅរកបង ទូរសព្ទដាច់ប្រើលែងកើតទៅហើយ! ហេតុការណ៍ស្រាប់តែក្រឡាប់ចាក់យ៉ាងនេះ ខ្ញុំវិលវល់ណាស់ ណាមួយអ្នកបងស្រាប់តែរស់វិញហើយនិយាយកុហកគេឯងថាខ្ញុំខឹងគាត់យកឡានបើកចេញពីផ្ទះទើបរងគ្រោះថ្នាក់ រីឯចូផ្កាដែលគាត់របូតដៃធ្វើបែកនោះ ក៏គាត់ពោលបំផ្លើសថាសត្វឆ្មាធ្វើបែកដែរ ប៉ុន្តែផ្ទះគ្មានឆ្កែឆ្មាមួយសោះ បងថាទៅមើល៍ ម៉េចក៏សុខៗ រឿងរ៉ាវប្រែជាក្រឡាប់ចាក់យ៉ាងនេះទៅវិញ!

ខ្ញុំឃើញគាត់ស្លាប់ផ្ទាល់នឹងភ្នែក ប៉ុន្តែគាត់បែរជានៅរស់ជ្រងោ ខ្ញុំមិនដឹងថាមកពីមូលហេតុអ្វីទេ ខ្ញុំគ្រាន់តែដឹងថាខ្ញុំចាំមិនច្រឡំឡើយ បងថ្លៃខ្ញុំបានស្លាប់បាត់ទៅហើយ គាត់ស្លាប់នៅចំពោះមុខខ្ញុំ គឺដៃខ្ញុំស្ទាបដង្ហើមគាត់ច្បាស់ណាស់!

កំលោះលើកដៃរាកាត់ ដោយស៊កសំណួរ៖

-ឈប់ភីណា! យប់នោះពួកអ្នកបម្រើទៅណាអស់!

ភីណាតបវិញភ្លាម៖

-គឺពួកគេគេងដូចស្លាប់! ខ្ញុំគោះទ្វារផង ស្រែកហៅផង អត់មានអ្នកកម្រើកទេ! ពូ សួសវិញខ្ញុំដើរទៅបន្ទប់គាត់យកសោឡានក៏គាត់មិនទាំងដឹងខ្លួនផង!

ក្រសែភ្នែកវិទូរេរិះគិតខ្វាច់។ នាងក្រមុំនៅបង្អង់ស្ងៀមលែងនិយាយ ប៉ុន្តែនាងមិនមានឮអ្នកកំលោះគូដណ្តឹងតបមកវិញមួយម៉ាត់ណាទាល់សោះ នាងងើបមុខសម្លឹងគេយ៉ាងមុត ហាក់ដូចជាចង់មើលឲ្យធ្លុះដល់អ្វីដែលគេកំពុងតែគិត ភ្លាមនោះនាងពោលសួរទៅកាន់វិទូដោយក្តីសង្ស័យ៖

-ឬមួយបងក៏មិនជឿសម្តីខ្ញុំទេ? ឬមួយបងគិតថាសរសៃប្រសាទខ្ញុំមានបញ្ហាវង្វេងវង្វាន់និយាយផ្តេសផ្តាស?

ពាក្យ សរសៃប្រសាទ ធ្វើឲ្យគេនឹកឃើញដល់ប្រអប់ថ្នាំក្នុងដៃ។ គេលើកបង្ហាញស្រី ដោយសួរមួយៗ៖

-ថ្នាំនេះអូនលេបរហូតមកមែនអ្ហេះភីណា?

ធីតាលូកដៃទទួលហើយងក់ក្បាលៗផ្ងក់ៗ។

វិទូសម្លឹងមកនាងក្រមុំភីណាមិនដកភ្នែក តាមពិតពាក្យសម្តីនាងទាំងប៉ុន្មានហួសវិស័យនឹងជឿកើតក៏ពិតមែន ប៉ុន្តែសម្លឹងមើលទឹកមុខរបស់នាង មិនសមថានិយាយផ្តេសផ្តាសសោះ ឬមួយថារឿងជាក់ស្តែងនៅខាងក្រៅក៏ដូចក្នុងខ្សែភាពយន្តដែរ? មនុស្សស្លាប់ហើយអាចរស់ឡើងវិញកើតដែរអ្ហេស៎? អ្នកកំលោះលូកមាត់ពោលសួរទៅកាន់ភីណាវិញ៖

-ម៉េចក៏រឿងធ្លាក់ជណ្តើរកាលពីយប់នោះ មិនដែលឮអ្នកបងនិយាយ?

ភីណាងាកមុខចេញដោយអាការហួសចិត្ត នាងឧទាន៖

-គាត់ស្លាប់ហើយបែរជារស់ឡើងវិញ គឺលែងជាមនុស្សធម្មតាទៀតហើយ បងទៅដែលបានជួបគាត់ប៉ុន្មានដងដែរ? គាត់មិនដែលចុះពីបន្ទប់មកក្រោមទេ សូម្បីតែពេលបាយ! តាមពិតគឺអ្នកបងក្លាយជាខ្មោចទៅហើយ ខ្ញុំបានឃើញគាត់លួចសាច់ឆៅក្នុងទូទឹកកកផ្ទាល់នឹងភ្នែក អញ្ចឹងហើយទើបមីងម៉ាប់រអ៊ូថាបាត់សាច់ឆៅរាល់តែថ្ងៃ! ហើយកាលពីព្រលឹមនេះ គាត់ប្រុងប្របាច់កខ្ញុំ  ប៉ុន្តែខ្ញុំនិយាយទៅបែរជាគ្មានអ្នកព្រមជឿសោះ បងប្រុសក៏អញ្ចឹង! បងឯងក៏មិនជឿខ្ញុំដែរ!

វិទូចម្លែកក្នុងចិត្ត តែទឹកមុខគេនៅស្មើធេង គេងាកមករកនាងក្រមុំភីណា ទាំងពោលប្រាប់មួយៗ៖

-ភីណា! បងមានការទៅមន្ទីរពេទ្យបន្តិច! ល្ងាចនេះបងមកវិញ! នៅផ្ទះបិទទ្វារចាក់សោឲ្យស្រួលសិន ហើយកុំដេញមីងម៉ាប់ទៅណា!ដឹងអត់! ចាំបងមកវិញសិនចាំគិតទៀត!

ភីណាដឹងថាទោះជាចង់ឃាត់ឲ្យគេនៅស្តាប់សម្តីខ្លួនក៏ឥតប្រយោជន៍ដែរ នាងងក់ក្បាលយឺតៗដោយគ្មានចេញស្តីមួយម៉ាត់ អ្នកកំលោះក្រោកឈរពោលមកកាន់នាងជាលើកចុងក្រោយ៖

-សម្រាកសិនទៅ! បងទៅសិនហើយ!

នាងក្រមុំក្រោកឈរជាកិច្ចជូនដំណើរអ្នកកំលោះគូស្នេហ៍ ប៉ុន្តែនាងមិនមានហើបមាត់និយាយមួយម៉ាត់ទៀតទេ។ វិទូសម្លឹងនាងបន្តិចទើបស្រវាឱបរាងកាយតូចតន់ក្នុងរង្វង់ដៃ ធ្វើឲ្យនាងយំសសិត។មុនឈានជើងចាកចេញទៅ គេខ្សឹបៗតិចៗកាត់កែវភ្នែកភីណាដែលសែនស្រងូតស្រងាត់។

-បងនឹងរកយុត្តិធម៌ឲ្យអូន! អត់ធ្មត់....ឮអត់!?

គេចាកចេញទៅជាមួយប្រអប់ថ្នាំក្នុងដៃ។ ទោះយ៉ាងណាសម្តីចុងក្រោយរបស់គេធ្វើឲ្យធីតាញញឹមទាំងទឹកភ្នែក។ ប្រិយមិត្តធ្លាប់ឃើញស្នាដៃបំបែកសំណុំរឿងរបស់ប៉ូលិសវិទូក្នុងរឿងស្វូឌីយោលេខ៧ហើយ តើជឿជាក់ថាគេអាចមានលទ្ធភាពបំបែកសំណុំរឿងម៉ោង១២អាធ្រាត្រកាលពីយប់ភ្លៀងធំនោះជូនគូដណ្តឹងខ្លួនបានដែរឬយ៉ាងណា?

វគ្គទី៧

សំណុំរឿង ម៉ោង១២អាធ្រាត្រ

-នេះជាថ្នាំបំពុលសរសៃប្រសាទ! លោកបានវាពីណាមក!

បុរសមជ្ឈិមវ័យដែលគ្រងដោយអាវវែងសក្បុសគ្របពីលើសម្លៀកបំពាក់របស់គាត់។ ទឹកមុខស្លូតបូតតែម៉ឹងម៉ាត់ ហើយគាត់បង្ហាញភាពងឿងឆ្ងល់លើផ្ទៃមុខដោយមានគ្រាប់ថ្នាំបីបួនក្នុងដៃផង។វិទូដាក់បង្គុយទៅលើសាឡុង តែមាត់និយាយ៖

-ក្រែងលោកជាអ្នកឲ្យថ្នាំនេះទៅភីណា?

លោកវេជ្ជបណ្ឌិតពិនិត្យប្រអប់ រួចងាកមករកគ្រាប់ថ្នាំម្តងបន្តិចមក ក៏ដោយឆ្លើយច្បាស់ៗ៖

-ប្រអប់នេះគឺមែន! តែថ្នាំនេះអត់ទេ!

វិទូមិននិយាយមួយម៉ាត់សោះ តែគេរវេក្នែករិះគិត។

"អញ្ចឹងភីណាបានថ្នាំនេះពីណាមក? "អ្នកសួរស្ងាត់ៗក្នុងចិត្ត។ លោកវេជ្ជបណ្ឌិតងើបមុខសម្លឹងមកកាន់ភ្នៀវគាត់ដៀងភ្នែកសម្លឹងគ្រាប់ថ្នាំលើដៃបន្តិច ទើបពោលមកកាន់ភ្ញៀវយឺតៗ៖

-ថ្នាំនេះត្រូវបានហាមប្រាមក្នុងវិស័យវេជ្ជសាស្ត្រ! វាបណ្តាលឲ្យមហន្តរាយដល់សុខភាពអ្នកជំងឺ ពិសេសប្រព័ន្ធខួរក្បាល! គេអាចរកទិញវាបានតែក្នុងផ្សារងងឹត វាជាសារធាតុញៀនសំយោគផ្សំរួមពីសារធាតុគីមីលាយឡំនឹងជាតិមេតំហ្វេតាមីនដែលអាចធ្វើឲ្យមនុស្សស្រមើស្រមៃ និងបំភ្លេចទុក្ខព្រួយ! នៅស្រុកខ្មែរយើង ការប្រើប្រាស់ និងការលក់ដូរសារជាតិនេះត្រូវបានហាមឃាត់ដោយច្បាប់!មន្ទីរពេទ្យយើងអត់មានរឿងអីត្រូវប្រើរបស់អស់នេះទៅកាន់អ្នកជំងឺទេ! ខ្ញុំសូមបដិសេធដាច់ខាត!

វិទូបើកភ្នែកមូលក្លុំសម្លឹងយ៉ាងយកចិត្តទុកដាក់ទៅកាន់លោកវេជ្ជបណ្ឌិត ក្នុងខណៈដែលដៃគាត់កំពុងហុចគ្រាប់ថ្នាំអ្នកវិញ ខណៈអ្នកឮគាត់បន្តវាចា៖

-អាការៈប្រែប្រួលរបស់គូដណ្តឹងលោកប្រាកដជាទាក់ទងនឹងការប្រើប្រាស់ថ្នាំនេះ!

-តើនាងប្រើវាតាំងពីមុនមក ឬមួយទើបតែប្រើក្រោយពេលចេញពីពេទ្យ?

លោកវេជ្ជបណ្ឌិតជ្រួញចិញ្ចើមបង្ហាញអាការៈអល់អែកគាត់ពោលយឺតៗដោយសម្លឹងផ្តោតមកកាន់នាយប៉ូលិសវ័យក្មេងដែលកំពុងរង់ចាំស្តាប់ចម្លើយ៖

-តាមពិតយើងមានវិធីវិភាគរឿងនេះដោយបូមឈាមនាងយកទៅ ប៉ុន្តែខ្ញុំសំណូមពរថាគួរតែទៅទាក់ទងនឹងអ្នកជំនាញសារធាតុញៀនល្អជាងដោយសារគេមានឯកទេសច្បាស់អាចធ្វើការវិភាគបានត្រឹមត្រូវជាង! ហើយគេក៏មានវិធីសាស្ត្របន្សាបមានប្រសិទ្ធភាពជាងខាងពួកខ្ញុំ!

វិទូផ្អែកខ្នងទៅនឹងបង្អែកដោយឱបដាប់ទៅដោយក្តីសង្ស័យយ៉ាងជ្រៅក្នុងចិត្ត។ ម៉េចក៏ទៅជាអញ្ចឹង? ការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមយុវវ័យអភិជនអត់មានអ្វីគួរឲ្យចម្លែកទេក្នុង

ពេលបច្ចុប្បន្ន តែបើឲ្យជឿថាភីណាក្នុងចំណោមយុវជនភ្លើតភ្លើនទាំងនោះ ដូចជាឆ្ងាយពីការពិតខ្លាំងពេក? ភ្លាមនោះអ្នកឮលោកវេជ្ជបណ្ឌិតពោលសួរវិញ៖

-ចុះហេតុអ្វីបានជាពេលនេះទើបលោកយកថ្នាំនេះមកសួរ? ចុះថ្នាំដែលខ្ញុំឲ្យនាងលេប ទៅឯណាអស់?

វិទូសម្លឹងមកម្ចាស់សំឡេងសន្ធនា នាយពោលតបវិញមួយៗដោយទឹកមុខនឹងន៖

-ត្រង់នេះហើយដែលខ្ញុំមករកការពន្យល់មួយ! ព្រឹកមិញខ្ញុំយកថ្នាំទៅឲ្យនាងព្រោះនាងភ្លេច តាមផ្លូវខ្ញុំជួបមិត្តម្នាក់ ក៏អង្គុយហូបកាហ្វេជជែកគ្នាលេង គេជាឱសថបណ្ឌិតដែរ ខ្ញុំក៏ចាក់គ្រាប់ថ្នាំនេះសួរគេ ព្រោះមួយរយៈនេះគូដណ្ដឹងខ្ញុំប្រែប្រួលខុសពីមុនពេក! ចម្លែកត្រង់ថាគេមិនវិភាគថ្នាំនេះចេញ បានន័យថាសូម្បីមិត្តខ្ញុំក៏មិនដែលបានឃើញវាពីមុនមកដែរ អញ្ចឹងហើយខ្ញុំក៏ឆៀងមកសួរលោក! ខ្ញុំគ្រាន់តែចង់បានចម្លើយថាតើនេះជាថ្នាំមន្ទីរពេទ្យចេញឲ្យនាង ឬក៏នាងបានពីកន្លែងផ្សេងណាមក!

លោកវេជ្ជបណ្ឌិតគ្រវីក្បាលយឺតៗបង្ហាញនូវភាពងឿងឆ្ងល់និងមិនអស់ចិត្ត គាត់ពោលរអ៊ូ៖

-ចុះថ្នាំដែលខ្ញុំឲ្យទៅណាវិញ?

វិទូក៏បង្ហាញនូវអាការទញ់ទាល់ដែរ។ គេនៅស្ងៀមដកដង្ហើមធំមួយខណៈ ទើបនិយាយឡើងថា៖

-ជម្រាបតាមត្រង់ទៅចុះថាពួកខ្ញុំក៏មិនទាន់ដឹងថាភីណាបានថ្នាំនេះពីណាមកដែរហើយនាងប្រើវាតាំងពីពេលណាមក! ប៉ុន្តែសំខាន់ពេលនេះខ្ញុំសូមលោកមេត្តាធ្វើយ៉ាងណាលាក់រឿងនេះឲ្យបានល្អដឹងត្រឹមលោកនិងខ្ញុំដោយឃោគយល់ដល់ការរាប់អានរវាងបងកុសលនិងលោក! ពួកខ្ញុំនិងអង្កេតករណីនេះឲ្យបានច្បាស់!

លោកវេជ្ជបណ្ឌិតងក់ក្បាលផ្ងក់ៗ ជាសញ្ញាថាមិនបដិសេធនូវសម្ដីរបស់អ្នកកំលោះទេ គាត់បន្លឺតប៖

-បាទ! លោកទុកចិត្តចុះ!

វិទូផ្ដោតភ្នែកសម្លឹងទៅកាន់លោកវេជ្ជបណ្ឌិត ប៉ុន្តែការពិតគឺអ្នកកំលោះកំពុងអញ្ចឹងគិត ឬមួយថាពាក្យសម្ដីចម្លែកៗរបស់ភីណា ជាមួយរឿងខុសប្រក្រតីនៃទំនាក់ទំនងរវាងនាង និងអ្នកស្រីវ័យក្មេង មានទាក់ទងគ្នានឹងថ្នាំនេះ។

កាលពីនៅផ្ទះអម្បាញ់មិញនាងបានរៀបរាប់ប្រាប់អ្នកថា កាលពីយប់នោះដែលក្នុងផ្ទះគ្មានអ្នកណានៅ មានតែនាងនិងបងថ្លៃប៉ុណ្ណោះ បងថ្លៃនាងបានទាក់ជើងដួលពីលើជណ្ដើរ ព្រោះតែរត់គេចពីមនុស្សចម្លែកពីរនាក់ដែលលួចចូលក្នុងបន្ទប់វត្ថុបុរាណ ហើយកាលដែលគាត់ទាក់ជើងដួលនោះ បានធ្លាក់មកជាន់ខាងក្រោម ណាមួយនាងបានបញ្ជាក់ថា គាត់បានបោកទង្គិចទៅនឹងជើងសាឡុងយ៉ាងដំណំ រហូតទាល់តែដាច់ដង្ហើមភ្លាមទៀតផង តើនេះជាការពិតដែលភីណាបានឃើញព្រោះតែភាពរវើរវាយក្រោមឥទ្ធិពលថ្នាំ? តើនាងពិតជាលេងថ្នាំញៀនសំយោគប្រភេទថ្មីនេះរហូតដល់សរសៃប្រសាទមានបញ្ហា? ប៉ុន្តែចុះហេតុអ្វីបានជាមុននេះនៅ Apartment ពេលខ្លួនលើកថ្នាំនេះបង្ហាញនាង នារីអភិជនដូចជាគ្មានរអៀសខ្លួនភិតភ័យឬភ្ញាក់ផ្អើលអ្វីសោះ?

វិទូលាពេទ្យត្រឡប់មកផ្ទះវិញ ដោយតាមផ្លូវអ្នកកំលោះត្រិះរិះពីបញ្ហាដ៏ស្មុគស្មាញនេះម្ដងហើយម្ដងទៀត។ នោះជាពេលរសៀល គាប់ជួនត្រូវជិះកាត់ផ្ទះភីណាផង កំសួលចិត្តមួយផ្ទុះឡើងភ្លាមក្នុងអារម្មណ៍អ្នកកំលោះវិទូ អ្នកកំលោះស្រាប់តែនឹកឃើញថាចង់ទៅជួបអ្នកស្រីកុលាបដើម្បីសាកសួរពីព្រឹត្តិការណ៍នានាទាក់ទងនឹងរបួសរបស់គូដណ្ដឹង។